


# ព្រឹត្តិបត្រ
# មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម



លេខ១

ឆ្នាំ២០២២

# កថាមុខ

រាជបណ្ឌិត្យសភាកម្ពុជាជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្ត និង អ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបាន រាជរដ្ឋាភិបាល ចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។ រាជបណ្ឌិត្យសភាកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យទាំងអស់ ដើម្បីផ្តល់ជាធាតុចូលជូនរាជរដ្ឋាភិបាល ដើម្បីបម្រើដល់កិច្ចការស្តារ និង អភិវឌ្ឍសេដ្ឋកិច្ចសង្គម។

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនដូចជា ស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម រួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួន ក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាព ភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភាកម្ពុជា។

ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្របានបង្កើត ព្រឹត្តិបត្រមួយដែលមានឈ្មោះថា «ព្រឹត្តិបត្រមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម» ដើម្បីរៀបចំ ចងក្រង និងបោះពុម្ពផ្សាយសកម្មភាពការងារនានា និងសកម្មភាពស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា។

«ព្រឹត្តិបត្រមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម» ប្រមូលផ្តុំដោយព័ត៌មានទាក់ទងនឹងសកម្មភាពការងារ កិច្ចប្រជុំ ការចូលរួមសិក្ខាសាលា សន្និសីទ សកម្មភាពចុះស្រាវជ្រាវតាមទីកន្លែងនានា របកគំហើញថ្មីៗ ក្នុងគោលបំណងចែករំលែកព័ត៌មានទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជាអ្នកអានទូទៅផងដែរ។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «ព្រឹត្តិបត្រមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជា នឹងផ្តល់នូវព័ត៌មានសម្រាប់ និស្សិត ក៏ដូចជាអ្នកស្រាវជ្រាវទូទៅ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២

**ប្រធានវិទ្យាស្ថាន**

និពន្ធនាយកៈ ឯកឧត្តមបណ្ឌិត **ផុន កសិកា**

ក្រុមត្រួតពិនិត្យៈ

១-លោក ឃិន យ៉ង់

២-លោក សួ ប៉ុណ្ណារ៉ាត់

៣-លោកស្រីបណ្ឌិត ជា វណ្ណី

៤-លោក លី តុង

៥-លោកបណ្ឌិត ឈឿន សាវន

៦-លោកបណ្ឌិត តូច សុធារី

៧-លោក ហៃ សុគន្ធា

រចនាគម្របៈ ឡុង សត្យា និង នេត ចំរើន

អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្សី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខរាជធានីភ្នំពេញ

(ជាប់បរិវេណសាកលវិទ្យាល័យភ្នំពេញ មណ្ឌល២)

គេហទំព័រ (Website) : https://ihss.rac.gov.kh

ហ្វេសប៊ុក (Facebook) : https:/web.facebook.com/វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

Institute of Humanities and Social Sciences (https://ihss.rac.gov.kh/)

ដើមទំព័រ - Institute of Humanities and Social Sciences

# មាតិកា

ទំព័រ


១-ឯកឧត្តមបណ្ឌិត **ផុន កសិកា** អញ្ជើញចូលជួបសម្តែងការគួរសម និងគោរពជូនពរឆ្នាំថ្មី ជូនឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ......................................................................១

២-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ......................................................................២

**៣-ទំព័រ កិច្ចសហប្រតិបត្តិការ** ......................................................................៣

៤-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ផ្តល់បទសម្ភាសន៍ ផ្សាយផ្ទាល់ក្នុងកម្មវិធី ព័ត៌មាន វេទិកា CNC ក្រោមប្រធានបទ **«ផ្នត់គំនិតនិងមោទនភាពរបស់ខ្មែរ ប្រៀបពីអតីតកាល-បច្ចុប្បន្ន»** ......................................................................៤

៥-លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** ចូលរួមប្រជុំគណៈកម្មការទី៥ នៃគណៈកម្មការស្តង់ដារជាតិ.......៥

៦-លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** ចូលរួមកិច្ចប្រជុំ ពិគ្រោះយោបល់លើការសិក្សាស្រាវជ្រាវស្តីពី **លទ្ធភាពក្នុងការផ្លាស់ប្តូរ រថយន្តដឹកកម្មករនិយោជិតដែលមិនមានសុវត្ថិភាព មកជារថយន្តដែលមានសុវត្ថិភាពប្រសើរជាង** ......................................................................៦

៧-លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** ចូលរួមកិច្ចប្រជុំ ពិភាក្សាលើសេចក្តីព្រាងឯកសារស្ថានភាព ភាគលាភប្រជាសាស្ត្រ និងយែនឌ័រនៅកម្ពុជា ......................................................................៧

៨-លោកស្រីបណ្ឌិត **ជា វណ្ណី** ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ លើសេចក្តីព្រាងឯកសារ ស្តីពី **ការវិភាគយេនឌ័រលើលទ្ធផល ជំរឿនប្រជាជនឆ្នាំ២០១៩** ......................................................................៨

៩-លោកបណ្ឌិត **ឈឿន សាវន** ចូលរួមក្នុងសិក្ខាសាលាផ្ទៀងផ្ទាត់ របាយការណ៍ «ការវាយតម្លៃផលប៉ះពាល់ លើសហគមន៍នៅតាម ដងទន្លេមេគង្គ និងទន្លេសាប ដោយសារទឹកទន្លេ មានកម្រិតទាប ក្នុងឆ្នាំ២០១៩ និង ២០២០» ......................................................................៩

១០-ឯកឧត្តមបណ្ឌិត **កង ឌិម** និងលោកបណ្ឌិត **សូ សុជីវ** ចូលរួមធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាលស្តីពី **«ការបណ្តុះបណ្តាលគ្រូបង្គោល»** ......................................................................១០

១១-លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** ចូលរួមក្នុង **វេទិកាប្រជាជន ពិភពលោក ១១ កក្កដា** ..........១១

១២-លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** ចូលរួមកិច្ចប្រជុំ ពិភាក្សាលើសេចក្តីព្រាងឯកសារ ស្ថានភាពភាគលាភប្រជាសាស្ត្រ និងយែនឌ័រនៅកម្ពុជា ......................................................................១២

១៣-លោកបណ្ឌិត **ឈឿន សាវន** ចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធី ពិភាក្សាស្តីពី «ឱកាស និងទស្សនៈវិស័យនៅពេលអនាគត នៃវិស័យទេសចរណ៍នៅប្រទេសកម្ពុជា» ..........................................១៤

១៤-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ដឹកនាំថ្នាក់ដឹកនាំវិទ្យាស្ថាន អញ្ជើញចូលរួមកម្មវិធីចុះអនុសារណៈ នៃការយោគយល់គ្នារវាងរាជបណ្ឌិត្យសភាកម្ពុជា ក្រុមហ៊ុនមេហូ និងក្រុមហ៊ុនហ្សិប ស៊ីល អ៊ិនស្តើរេសិន ផាតនើរ អេស៊ា ឯ.ក ......................................................................១៥

១៥-លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** ចូលរួមក្នុង កិច្ចប្រជុំពិគ្រោះយោបល់លើស្តីពី
សិទ្ធិជនពិការ ជូនមន្ត្រីរាជការនៃ ទីស្តីការគណៈរដ្ឋមន្ត្រី ..........................................................១៦
១៦-លោក **ហៃ សុគន្ធា** ចូលរួមជា វាគ្មិន ក្នុងសន្និសីទអន្តរជាតិ លើកទី១
នៃក្រុមការងារ អ្នកភូមិវិទ្យាវ័យក្មេងទ្វីបអាស៊ី ..........................................................១៧
១៧-លោកបណ្ឌិត **សូ សុធីរ** ចូលរួមក្នុង វេទិកានិងពិព័រណ៍អប់រំវិជ្ជាជីវៈអាស៊ាន-ចិន ..............................១៨
១៨-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមក្នុងកិច្ចប្រជុំរវាងរាជបណ្ឌិត្យសភាកម្ពុជា ជាមួយគណៈប្រតិភូ
មកពីវិទ្យាស្ថានវិទ្យាសាស្ត្រឥណ្ឌូនេស៊ី ..........................................................១៩
១៩-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមក្នុងជំនួបជាមួយឯកឧត្តម Anatoly Borovik អគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ......២០
២០-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមក្នុងជំនួបជាមួយឯកឧត្តម Benjamin Wohlauer
អនុប្រធានបេសកកម្មនៃស្ថានទូតសហរដ្ឋអាម៉េរិក ..........................................................២១
២១-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមក្នុងជំនួបជាមួយលោកជំទាវ Mrs.Liurka Rodriguez Barrios,
ឯកអគ្គរាជទូតនៃសាធារណរដ្ឋគុយបា ..........................................................២២
**២២-ទំព័រ សកម្មភាពការងារក្នុងក្របខណ្ឌវិទ្យាស្ថាន ..........................................................២៣**
២៣-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
ដឹកនាំប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០២១ របស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ..............២៤
២៤-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំក្រុម
ការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ខែតុលា ..........................................................២៦
២៥-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំ
ការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ខែសីហា ..........................................................២៧
២៦-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំ
ការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ខែកក្កដា ..........................................................២៩
២៧-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំក្រុម
ការងារស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ..........................................................៣១
២៨-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំក្រុម
ការងារស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ..........................................................៣២
២៩-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំ
បូកសរុបការងារឆ្នាំ២០២០ និងលើកផែនការការងារឆ្នាំ២០២១ ..........................................................៣៣
៣០-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំ
រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ..............................៣៤
៣១-ការរៀបចំការិយាល័យថ្មីនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៅអគារខេមរវិទូ ..................៣៥
**៣២-ទំព័រកិច្ចប្រជុំនិងការងារក្នុងក្របខណ្ឌ រាជបណ្ឌិត្យសភាកម្ពុជា ..........................................................៣៦**

៣៣-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមសន្និសីទអន្តរជាតិលើកទី១៦ ស្តីពី បរិបទថ្មី
នៃទំនាក់ទំនងអាស៊ាន-កូរ៉េ ....................................................................................៣៧
៣៤-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមសន្និសីទអន្តរជាតិ ស្តីពី តួនាទីរបស់ចិនក្នុងសតវត្សទី២១
និងទំនាក់ទំនងរបស់ចិនជាមួយអាស៊ាន ........................................................................៣៩
៣៥-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមសន្និសីទអន្តរជាតិ ស្តីពី យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក
និងការទូតរបស់រដ្ឋតូចៗ ..........................................................................................៤០
៣៦-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
អញ្ជើញចូលរួមពិធីសូត្រមន្ត អគារខេមរវិទូ ...................................................................៤១
៣៧-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមកិច្ចប្រជុំ
ស្តីពីដំណើរការប្រព្រឹត្តទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា ....................................................៤២
៣៨-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំនៃរាជបណ្ឌិត្យសភាកម្ពុជា ស្តីពី
«ដំណើរវិវត្តន៍ស្ថានភាពនយោបាយក្នុងប្រទេសមីយ៉ាន់ម៉ា» .................................................៤៣
៣៩-ឯកឧត្តមបណ្ឌិត **ផុន កសិកា** អញ្ជើញចុះអនុស្សារណៈយោគយល់គ្នារវាង «វិទ្យាស្ថានមនុស្សសាស្ត្រ
និងវិទ្យាសាស្ត្រសង្គម និងវិទ្យាស្ថានបេតិកភណ្ឌវប្បធម៌នៃសាកលវិទ្យាល័យវ៉ាសេដា .........................៤៤
៤០-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមប្រជុំ
ក្នុងជំនួបជាមួយឯកអគ្គរាជទូតក្រភពអង់គ្លេស ប្រចាំប្រទេសកម្ពុជា ......................................៤៥
៤១-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
ចូលរួមប្រជុំ Brainstorm ........................................................................................៤៦
៤២-លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** ចូលរួមប្រជុំប្រធាន-អនុប្រធានក្រុមបច្ចេកសព្ទ
នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ .....................................................................................៤៧
៤៣-ថ្នាក់ដឹកនាំនិងមន្ត្រី វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមផ្តល់បទសម្ភាសន៍ដល់
ក្រុមការងារបច្ចេកទេស រៀបចំផែនការយុទ្ធសាស្ត្ររាជបណ្ឌិត្យសភាកម្ពុជា ...............................៤៨
៤៤-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ចូលរួម
កិច្ចពិភាក្សាតុមូល ស្តីពី សារៈសំខាន់នៃការស្រាវជ្រាវ ...................................................៤៩
៤៥-លោក **ហៃ សុគន្ធា** ចូលរួមក្នុងគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ...........................................៥០
៤៦-លោក **ហៃ សុគន្ធា** ចូលរួមពិភាក្សាកិច្ចការ ជាមួយក្រុមការងារគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ....៥៥
៤៧-លោកស្រីបណ្ឌិត **ជា វណ្ណី** ចូលរួមធ្វើជាវាគ្មិន ស្តីពី **ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ** .........................៥៦
៤៨-ការចូលរួមកែលម្អបរិស្ថានធម្មជាតិនៅរាជបណ្ឌិត្យសភាកម្ពុជា របស់មន្ត្រីវិទ្យាស្ថាន
មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ...........................................................................៥៧
**៤៩-ទំព័រការងារស្រាវជ្រាវ ...........................................................................................៥៩**
**៥០-ការអនុវត្តគម្រោងស្រាវជ្រាវ «សរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា» ........................................៦០**

៥១-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានលេខាធិការដ្ឋានគម្រោង សរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា រៀបចំកិច្ចប្រជុំ ពិភាក្សាស្តីពី ការសម្រេចមាតិកាតាមក្រុមសម័យកាលនីមួយៗ........................................៦៣
៥២-លោកបណ្ឌិត **វង់ សុជាំ** ប្រធានក្រុមសម័យអង្គរ ដឹកនាំកិច្ចប្រជុំរៀបចំមាតិកាប្រវត្តិសាស្ត្រសម័យអង្គរ ......៦៤
៥៣-ឯកឧត្តមបណ្ឌិត **ជូ ច័ន្ទដារី** ប្រធានក្រុមសម័យទំនើប ដឹកនាំកិច្ចប្រជុំរៀបចំមាតិកាប្រវត្តិសាស្ត្រ សម័យទំនើប ..................................................................................................................៦៥
៥៤-លោកបណ្ឌិត **វង់ សុជាំ** ប្រធានក្រុមសម័យអង្គរ ដឹកនាំកិច្ចប្រជុំរៀបចំមាតិកាប្រវត្តិសាស្ត្រសម័យអង្គរបន្ត ..៦៦
៥៥-ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមការអនុវត្តគម្រោងស្រាវជ្រាវ **«សរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា»**..............................................................................៦៧
**៥៦-ការអនុវត្តគម្រោងស្រាវជ្រាវ «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ច និងសង្គមកម្ពុជា»**.....................................................................**៦៨**
៥៧-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានគម្រោងស្រាវជ្រាវស្តីពី **«កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរី កម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា»** ដឹកនាំកិច្ចប្រជុំស្រាវជ្រាវគម្រោង ខែសីហា ..........................................................................៧០
៥៨-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានគម្រោងស្រាវជ្រាវស្តីពី **«កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរី កម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា»** ដឹកនាំកិច្ចប្រជុំស្រាវជ្រាវគម្រោង ខែមិថុនា ..........................................................................៧១
៥៩-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានគម្រោងស្រាវជ្រាវស្តីពី **«កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរី កម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា»** ដឹកនាំកិច្ចប្រជុំស្រាវជ្រាវគម្រោង ខែឧសភា ..........................................................................៧២
៦០-ឯកឧត្តមបណ្ឌិត **ផុន កសិកា** និងក្រុមការងារ ចុះសិក្សាស្រាវជ្រាវ ស្វែងយល់ពី **ប្រវត្តិប្រាសាទដូនអននិងសក្តានុពលទេសចរណ៍**.......................................................................៧៤
៦១-លោកបណ្ឌិត **ឈឿន សាវន** ចុះសិក្សាស្រាវជ្រាវនៅ **សហគមន៍អេកូទេសចរណ៍ធម្មជាតិកោះទ្រុង** ..............៧៥
៦២-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ដឹកនាំកិច្ចប្រជុំរៀបចំកលិកប័ត្រមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ................៧៦
៦៣-ឯកឧត្តមបណ្ឌិត **ផុន កសិកា** និងក្រុមការងារ ចុះសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមអំពី **«ប្រព័ន្ធជារាសាស្ត្រនៅភាគខាងជើងបន្ទាយលង្វែក»**.......................................................................៧៨
៦៤-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម សហការជាមួយអ្នកស្រាវជ្រាវអន្តរជាតិមកពីសាលាបារាំងចុងបូព៌ា ធ្វើការសិក្សាស្រាវជ្រាវនៅតំបន់ស្រុកឆែប ខេត្តព្រះវិហារ....៨០
៦៥-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ប្រជុំពិភាក្សាជាមួយលោកបណ្ឌិត Brice Vincent ប្រធានសាលាបារាំងចុងបូព៌ា ..............................៨២
៦៦-ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ទទួលជួបពិភាក្សាការងារជាមួយលោក **ហង្ស និស្ស័យ** ប្រធានសារមន្ទីរទួលស្លែង ..............................៨៣

៦៧-ការងារយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថាន ..........................................................................................៨៤
៦៨-ការងារថតវីដេអូឯកសាររបស់វិទ្យាស្ថាន ..........................................................................................៨៦
**៦៩-ទំព័រការងារសង្គម ..........................................................................................................៨៧**
៧០-ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមរំលែកមរណទុក្ខក្រុមគ្រួសារ
ថ្នាក់ដឹកនាំនិងមន្ត្រី នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលមានសមាជិកគ្រួសារទទួលមរណភាព ..........................៨៨
៧១-ឯកឧត្តមបណ្ឌិត **ផុន កសិកា** អញ្ជើញចុះស្វែងយល់ពី ស្ថានភាពទូទៅរបស់ប្រជាពលរដ្ឋ នៅភូមិព្រៃដក់ពរ .....៩១

# ឯកឧត្តមបណ្ឌិត ផុន កសិកា អញ្ជើញចូលជួបសម្តែងការគួរសម និងគោរពជូនពរឆ្នាំថ្មី ជូនឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ នៅរសៀលថ្ងៃអង្គារ ទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា អមដំណើរដោយ លោក **ឃិន យ៉ង់** និងលោក **សួ ប៊ុណ្ណារ៉ាត់** ក្នុងនាមឯកឧត្តម លោកជំទាវ លោក លោកស្រីជា ថ្នាក់ដឹកនាំ ជំនួយការ និងមន្ត្រី ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមទាំងអស់ បានចូលជួបសម្តែងការគួរសម និងគោរពជូនពរបវរសួស្តី សិរីមង្គលឆ្នាំថ្មី ឆ្នាំសាកល ឆ្នាំ២០២២ ជូនឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

ក្នុងឱកាសនោះដែរ ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានបានថ្លែងអំណរគុណ និងជូនពរថ្នាក់ដឹកនាំ ជំនួយការ និងមន្ត្រី វមវស ទាំងអស់ សូមប្រកបតែនឹង សេចក្តីសុខចម្រើនគ្រប់ប្រការ និងជោគជ័យគ្រប់ភារកិច្ច ចាកឆ្ងាយរោគា ទាំងពួង។

សូមជម្រាបជូនផងដែរថា ដោយសារបរិបទកូវីដ និងពេលវេលាកំណត់ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ពុំបានអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីទាំងអស់ចូលរួមក្នុងកម្មវិធីជូនពរនេះឱ្យបានគ្រប់ៗគ្នា ដូចកាលឆ្នាំកន្លងទៅ។ យើងខ្ញុំសង្ឃឹមជឿជាក់ថា នាឱកាសក្រោយៗ យើងនឹងបានចូលរួមគ្រប់ៗគ្នា ក្នុងកម្មវិធីនានារបស់ រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាកម្មវិធីជួបជុំរបស់វិទ្យាស្ថាន បន្ទាប់ពីការធូរស្រាលនៃជំងឺរាតត្បាតកូវីដនេះ។



# ឯកឧត្តមបណ្ឌិត ផុន កសិកា
# ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
# ចូលរួម ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅវេលាព្រឹកថ្ងៃសុក្រ ទី២២ ខែតុលា ឆ្នាំ២០២១ ចាប់ពីម៉ោង ៨ និង ៣០នាទី តទៅ ឯកឧត្តម បណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា និង លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** អនុប្រធានវិទ្យាស្ថាន រួមជាមួយថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជា និងថ្នាក់ដឹកនាំវិទ្យាស្ថានដទៃទៀតជាឧបសម្ព័ន្ធនៃរាជបណ្ឌិត្យសភាកម្ពុជា បានអញ្ជើញចូលរួម ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តាមរយៈប្រព័ន្ធវីដេអូខន់ហ្វីរេន នៅសាលប្រជុំសោតទស្សន៍ នៃរាជបណ្ឌិត្យសភាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។



# កិច្ចសហប្រតិបត្តិការ

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ផ្តល់បទសម្ភាសន៍ ផ្សាយផ្ទាល់ក្នុងកម្មវិធី ព័ត៌មាន វេទិកា CNC ក្រោមប្រធានបទ៖ «ផ្នត់គំនិតនិងមោទនភាពរបស់ខ្មែរប្រៀបពីអតីតកាល-បច្ចុប្បន្ន»

នៅថ្ងៃព្រហស្បតិ៍ ទី១៥ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជាផ្តល់បទសម្ភាសន៍ ផ្សាយផ្ទាល់ក្នុងកម្មវិធី ព័ត៌មាន វេទិកា CNC ក្រោមប្រធានបទ៖ «ផ្នត់គំនិតនិងមោទនភាពរបស់ខ្មែរប្រៀបពីអតីតកាល-បច្ចុប្បន្ន»..



# លោកបណ្ឌិតសភាចារ្យបម្រុង ឆេង វណ្ណារិទ្ធ
# ចូលរួមប្រជុំគណៈកម្មការទី៥ នៃគណៈកម្មការស្តង់ដារជាតិ

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានចូលរួមប្រជុំគណៈកម្មការទី៥ នៃគណៈកម្មការស្តង់ដារជាតិ តាមប្រព័ន្ធអនឡាញ ZOOM Meeting។



# លោកស្រីបណ្ឌិតសភាចារ្យបម្រុង ព្រុំ ទេវី ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើការសិក្សាស្រាវជ្រាវស្តីពី លទ្ធភាពក្នុងការផ្លាស់ប្តូររថយន្តដឹកកម្មករនិយោជិតដែលមិនមានសុវត្ថិភាព មកជារថយន្តដែលមានសុវត្ថិភាពប្រសើរជាង

នៅព្រឹកថ្ងៃសុក្រ ១០រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ចាប់ពីម៉ោង ៨៖០០ ដល់ម៉ោង ១១៖៣០ លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើការសិក្សាស្រាវជ្រាវ ស្តីពី **លទ្ធភាពក្នុងការផ្លាស់ប្តូររថយន្តដឹកកម្មករនិយោជិតដែលមិនមានសុវត្ថិភាព មកជារថយន្តដែលមានសុវត្ថិភាពប្រសើរជាង** តាមប្រព័ន្ធហ្សូម របស់អង្គការមូលនិធិបង្ការរបួសអាស៊ី (SAFE ROAD FOR LIFE) តាមការចាត់តាំងរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។



# លោកស្រីបណ្ឌិតសភាចារ្យបម្រុង ព្រុំ ទេវី ចូលរួមកិច្ចប្រជុំ ពិភាក្សាលើសេចក្តីព្រាងឯកសារស្ថានភាពភាគលាភប្រជាសាស្ត្រ និងយែនឌ័រនៅកម្ពុជា

នៅព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ចាប់ពីម៉ោង ៨៖៣០ ដល់ម៉ោង ១២៖០០ លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងឯកសារ **ស្ថានភាពភាគលាភប្រជាសាស្ត្រនិងយែនឌ័រនៅកម្ពុជា** តាមរយៈ ប្រព័ន្ធអនឡាញ Zoom meeting រៀបចំឡើងដោយ ក្រសួងផែនការ តាមការចាត់តាំងរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។



# លោកស្រីបណ្ឌិត ជា វណ្ណី ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ លើសេចក្តីព្រាងឯកសារ ស្តីពី ការវិភាគយេនឌ័រលើលទ្ធផលជំរឿនប្រជាជនឆ្នាំ២០១៩

នៅថ្ងៃសុក្រ ៦កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ លោកស្រីបណ្ឌិត **ជា វណ្ណី** ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និងយេនឌ័រ បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារ ស្តីពី **ការវិភាគយេនឌ័រលើលទ្ធផលជំរឿនប្រជាជន ឆ្នាំ២០១៩** រៀបចំឡើងដោយក្រសួងកិច្ចការនារី ដែលកិច្ចប្រជុំបានបញ្ចប់នាម៉ោង១២ និង៣០នាទី។



# លោកបណ្ឌិត ឈឿន សាវន
# ចូលរួមក្នុងសិក្ខាសាលាផ្ទៀងផ្ទាត់របាយការណ៍ «ការវាយតម្លៃផលប៉ះពាល់លើសហគមន៍នៅតាម ដងទន្លេមេគង្គ និងទន្លេសាប ដោយសារទឹកទន្លេ មានកម្រិតទាប ក្នុងឆ្នាំ២០១៩ និង ២០២០»

តាមការចាត់តាំងពីសំណាក់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា នៅព្រឹកថ្ងៃសុក្រ ១៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ លោកបណ្ឌិត **ឈឿន សាវន** ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងទេសចរណ៍ និងលោកបណ្ឌិត **តូច សុធារី** មន្ត្រីនាយកដ្ឋាន បានចូលរួមក្នុងសិក្ខាសាលាផ្ទៀងផ្ទាត់របាយការណ៍សិក្សា «ការវាយតម្លៃផលប៉ះពាល់លើសហគមន៍នៅតាមដងទន្លេមេគង្គ និងទន្លេសាប ដោយសារទឹកទន្លេ មានកម្រិតទាប ក្នុងឆ្នាំ២០១៩ និង ២០២០» ដែលបានរៀបចំដោយ វេទិកានៃអង្គការមិនមិនរដ្ឋាភិបាល ស្តីពី កម្ពុជា។



# ឯកឧត្តមបណ្ឌិត កង ឱម និងលោកបណ្ឌិត សូ សុធីរ ចូលរួមធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពី «ការបណ្ដុះបណ្ដាលគ្រូបង្គោល»

ចាប់ពីថ្ងៃទី១៦ ដល់ទី១៨ ខែសីហា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **កង ឱម** ជំនួយការ រាជបណ្ឌិត្យសភាកម្ពុជា ទទួលបន្ទុកជួយការងារ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម និង លោកបណ្ឌិត **សូ សុធីរ** មន្ត្រីស្រាវជ្រាវជាន់ខ្ពស់ នៃនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានអញ្ជើញចូលរួមជាគ្រូឧទ្ទេស ធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពី **«ការបណ្ដុះបណ្ដាលគ្រូបង្គោល (Training of Trainers)»** ដែលរៀបចំដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រាជបណ្ឌិត្យសភាកម្ពុជា
ខុទ្ទកាល័យ
Royal Academy of Cambodia
Académie Royale du Cambodge

Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, Email: info@rac.gov.kh, P.O. Box 531 Phnom Penh, Cambodia


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លោកបណ្ឌិតសភាចារ្យបម្រុង ឆេង វណ្ណារិទ្ធ បានចូលរួមក្នុង វេទិកាប្រជាជន ពិភពលោក ១១ កក្កដា

នៅថ្ងៃអង្គារ ទី២០ ខែកក្កដា ឆ្នាំ២០២១ តាមការចាត់តាំងរបស់ ឯកឧត្តមបណ្ឌិត សភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមក្នុង **វេទិកាប្រជាជនពិភពលោក ១១ កក្កដា** តាមរយៈប្រព័ន្ធអនឡាញ Zoom meeting រៀបចំដោយ ក្រសួងផែនការ។



# លោកស្រីបណ្ឌិតសភាចារ្យបម្រុង ព្រុំ ទេវី ចូលរួមកិច្ចប្រជុំ ពិភាក្សាលើសេចក្តីព្រាងឯកសារស្ថានភាពភាគលាភប្រជាសាស្ត្រ និងផែនទីបង្ហាញផ្លូវនៅកម្ពុជា

នៅព្រឹកថ្ងៃសុក្រ ទី២៣ ខែកក្កដា ឆ្នាំ២០២១ តាមការចាត់តាំងរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមក្នុងកិច្ចពិភាក្សាស្តីពី **គោលនយោបាយ និងប្រព័ន្ធសុវត្ថិភាពសង្គម និង បរិស្ថានរបស់អន្តរធនាគារ និងហិរញ្ញវត្ថុ ក្នុងការការពារប្រជាពលរដ្ឋដែលរស់នៅក្នុង ឬជុំវិញតំបន់គម្រោងអភិវឌ្ឍន៍នានា** តាមរយៈព្រព័ន្ធអនឡាញ Zoom meeting ដែលរៀបចំឡើងដោយ វេទិកា នៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ក្នុងគោលបំណង៖

១-ផ្តល់ការយល់ដឹងដល់សាធារណជនអំពី គោលនយោបាយ និងប្រព័ន្ធសុវត្ថិភាពសង្គម និង បរិស្ថានរបស់អន្តរធនាគារ និងវិស័យហិរញ្ញវត្ថុសម្រាប់ គម្រោងដែលទទួលបានជំនួយឥតសំណង ឬកម្ចីពីអន្តរធនាគារ ឬធនាគារក្នុងស្រុក

២-ផ្តល់ឱកាសដល់អន្តរធនាគារ ឬអ្នកពាក់ព័ន្ធ បានស្វែងយល់បន្ថែមពីតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តគោលនយោបាយ និងប្រព័ន្ធសុវត្ថិ ភាពសង្គម និងបរិស្ថាននាពេលកន្លងមក។



ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង　Working Together for ...

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

NGOF: ០៥៥៦...../SEED/២០២១

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**កម្មវត្ថុ៖** សំណើសូមអនុញ្ញាត **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាចាត់មន្ត្រី ០១រូប ចូលរួមជាភ្ញៀវកិត្តិយស និងពិភាក្សា ក្នុងកិច្ចពិភាក្សា ស្តីពី គោលនយោបាយ និងប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថានរបស់អន្តរធនាគារ និងវិស័យហិរញ្ញវត្ថុ ក្នុងការការពារប្រជាពលរដ្ឋដែលរស់នៅក្នុង ឬជុំវិញតំបន់គម្រោងអភិវឌ្ឍន៍នានា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ តាងនាមឱ្យវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាជ្រាបថា៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអង្គការដៃគូ បានសហការគ្នារៀបចំកិច្ចពិភាក្សាលើប្រធានបទ ស្តីពី "គោលនយោបាយ និងប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថានរបស់អន្តរធនាគារ និងវិស័យហិរញ្ញវត្ថុ ក្នុងការការពារប្រជាពលរដ្ឋដែលរស់នៅក្នុង ឬជុំវិញតំបន់គម្រោងអភិវឌ្ឍន៍នានា" ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ តាមរយៈតំណរ Zoom** ក្នុងគោលបំណងដើម្បី៖

១. ផ្តល់ការយល់ដឹងដល់សាធារណៈជន អំពី គោលនយោបាយ និងប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថានរបស់អន្តរធនាគារ និងវិស័យហិរញ្ញវត្ថុ សម្រាប់ការអនុវត្តគម្រោងដែលទទួលបានជំនួយឥតសំណង ឬកម្ចីពីអន្តរធនាគារ ឬធនាគារក្នុងស្រុក

២. ផ្តល់ឱកាសដល់អន្តរធនាគារ និងអ្នកពាក់ព័ន្ធបានស្វែងយល់បន្ថែមពីតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តគោលនយោបាយ និងប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថាននាពេលកន្លងមក។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាចាត់មន្ត្រី ០១រូប ចូលរួមកិច្ចពិភាក្សាខាងលើ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១៥រោច ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

**នាយកប្រតិបត្តិ**

**បណ្ឌិត ទឹក វណ្ណារ៉ា**

សូមភ្ជាប់ជូនជាមួយមកនូវ៖
- របៀបវារៈនៃកិច្ចពិភាក្សា និងសំណួរគន្លឹះ៖ ចំនួន ០១ច្បាប់

សូមមេត្តាផ្តល់ព័ត៌មានត្រឡប់មក៖
កញ្ញា វណ្ណធី សូរីដា ជំនួយការកម្មវិធី សមធម៌ សេដ្ឋកិច្ចសង្គមក្នុងការអភិវឌ្ឍន៍ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
ទូរស័ព្ទលេខ៖ ០៧៨ ៥០១ ០០៨ / ០៩៣ ៩៥៦ ០៦៨
អ៊ីមែល: sorida@ngoforum.org.kh

ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ... ភ្នំពេញ-៣　#9-11, St 476, Toul Tompoung1, Phnom Penh, P.O. Box 2295 Phnom Penh-3
Tel: (855) 23 214 429　Fax: (855) 23 994 063　E-mail: info@ngoforum.org.kh　Website: www.ngoforum.org.kh



FAIR FINANCE CAMBODIA
A MEMBER OF FAIR FINANCE ASIA
The NGO Forum on Cambodia
Co-organized by
Sverige
Diakonia
OXFAM
Supported by
កិច្ចពិភាក្សាស្តីពីគោលនយោបាយ និងប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថានរបស់
អន្តរធនាគារ និងហិរញ្ញវត្ថុ ក្នុងការការពារប្រជាពលរដ្ឋដែលរស់នៅក្នុង
ឬជុំវិញតំបន់គម្រោងអភិវឌ្ឍន៍
Discussion on Social and Environmental Safeguard Policies and Systems of Interbank and Financial Sectors to Protect People Living in or around the Development Projects Areas
Friday 23rd July 2021 8:30 - 12:00 PM
មតិស្វាគមន៍ បើក និងបិទកម្មវិធី
Welcome, Opening and Closing Remark
អ្នកសម្របសម្រួលកិច្ចពិភាក្សា
Moderator
វាគ្មិនជំនាញ
Guest Speakers
Ms. Elsie Gung
Mr. Lin Shiqiang
President of Industrial and Commercial Bank of China (ICBC)
THE ASSOCIATION OF BANKS IN CAMBODIA
THE WORLD BANK
ICBC
BANK OF CHINA
Cambodia Microfinance Association
zoom
LIVE

# លោកបណ្ឌិត ឈឿន សារេន ចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធី ពិភាក្សាស្តីពី «ឱកាស និងទស្សនៈវិស័យនៅពេលអនាគត នៃវិស័យទេសចរណ៍នៅប្រទេសកម្ពុជា»

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ចាប់ពីម៉ោង ១៥៖០០ តទៅ តាមការចាត់តាំងរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឆ្លើយតបតាមការអញ្ជើញរបស់ សមាគមទេសចរណ៍កម្ពុជា លោកបណ្ឌិត **ឈឿន សារេន** ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ច និងទេសចរណ៍ បានចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធី ពិភាក្សាស្តីពី **«ឱកាស និងទស្សនៈវិស័យនៅពេលអនាគតនៃវិស័យទេសចរណ៍នៅប្រទេសកម្ពុជា»** តាមរយៈប្រព័ន្ធអនឡាញ Zoom Meeting។






# ឯកឧត្តមបណ្ឌិត ផុន កសិកា ដឹកនាំថ្នាក់ដឹកនាំវិទ្យាស្ថាន អញ្ជើញចូលរួមកម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជបណ្ឌិត្យសភាកម្ពុជា ក្រុមហ៊ុនមេហូ និងក្រុមហ៊ុនហ្សិប ស៊ីល អ៊ិនស្ទើរេសិន ផាតនើរ អេស៊ា ឯ.ក

នៅព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ថ្នាក់ដឹកនាំវិទ្យាស្ថានមនុស្សសាស្រ្តនិងវិទ្យាសាស្រ្តសង្គម ដឹកនាំដោយឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** អនុប្រធានវិទ្យាស្ថាន លោក **ឃិន យ៉ង់** ទទួលបន្ទុកនាយកដ្ឋានកិច្ចការទូទៅ បានចូលរួមកម្មវិធីចុះអនុស្សរណៈ នៃការយោគយល់គ្នារវាង រាជបណ្ឌិត្យសភាកម្ពុជា ក្រុមហ៊ុនមេហូ និងក្រុមហ៊ុនហ្សិបស៊ីល អ៊ិនស្ទើរេសិន ផាតនើរ អេស៊ា ឯ.ក នាសាលមរតកសិល្បៈខ្មែរ ជាន់ទី៤ អគារតេជោនិងទេវី ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។







# លោកបណ្ឌិតសភាចារ្យបម្រុង ឆេង វណ្ណារិទ្ធ ចូលរួមក្នុង កិច្ចប្រជុំពិគ្រោះយោបល់លើស្តីពីសិទ្ធិជនពិការ ជូនមន្ត្រីរាជការនៃ ទីស្តីការគណៈរដ្ឋមន្ត្រី

នៅថ្ងៃអង្គារ ទី១៩ ខែមករា ឆ្នាំ២០២១ តាមការចាត់តាំងរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា លោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើស្តីពីសិទ្ធិជនពិការ ជូនមន្ត្រីរាជការនៃ ទីស្តីការគណៈរដ្ឋមន្ត្រី។






# លោក ហៃ សុគន្ធា ចូលរួមជា វាគ្មិន ក្នុងសន្និសីទអន្តរជាតិ លើកទី១ នៃក្រុមការងារ អ្នកភូមិវិទ្យាវ័យក្មេងទ្វីបអាស៊ី

ដោយបានការអនុញ្ញាតពី ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឆ្លើយតបតាមការអញ្ជើញរបស់ភាគីរៀបចំកម្មវិធី នៅ ថ្ងៃទី១៨-១៩ ខែធ្នូ ឆ្នាំ២០២១ លោក **ហៃ សុគន្ធា** មន្ត្រីស្រាវជ្រាវជាន់ខ្ពស់ តំណាងនាយកដ្ឋានភូមិវិទ្យា និងនគរូបនីយកម្ម បានចូលរួមជាវាគ្មិន ក្នុង**សន្និសីទអន្តរជាតិលើកទី១ នៃក្រុមការងារអ្នកភូមិវិទ្យាវ័យក្មេងទ្វីបអាស៊ី** តាមរយៈប្រព័ន្ធអនឡាញ ZOOM Meeting។



# លោកបណ្ឌិត សូ សុធីរ ចូលរួមក្នុង
# វេទិកានិងពិព័រណ៍អប់រំវិជ្ជាជីវៈអាស៊ាន-ចិន

ដោយបានការអនុញ្ញាតពី ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឆ្លើយតបតាមការអញ្ជើញរបស់ភាគីរៀបចំកម្មវិធី នៅថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០២១ លោកបណ្ឌិត **សូ សុធីរ** មន្ត្រីស្រាវជ្រាវជាន់ខ្ពស់នាយកដ្ឋានវិទ្យាសាស្ត្រអប់រំ បានចូលរួមក្នុង វេទិកានិងពិព័រណ៍អប់រំវិជ្ជាជីវៈអាស៊ាន-ចិន China-ASEAN Vocational Education Exhibition and Forum On-line, 2021 ដែលរៀបចំដោយ THE PEOPLE´S GOVERNMENT OF GUANGXI ZHUANG AUTONOMOUS REGION, THE PEOPLE´S REPUBLIC OF CHINA។



# ឯកឧត្តមបណ្ឌិត ផុន កសិកា ចូលរួមក្នុងកិច្ចប្រជុំរវាងរាជបណ្ឌិត្យសភាកម្ពុជា ជាមួយគណៈប្រតិភូមកពីវិទ្យាស្ថានវិទ្យាសាស្ត្រឥណ្ឌូនេស៊ី

នៅរសៀលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ ដោយបានការអនុញ្ញាតពីឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធាន រាជបណ្ឌិត្យសភាកម្ពុជា ឯកឧត្តមបណ្ឌិត **ផុន កសិកា** បានចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញរវាង រាជបណ្ឌិត្យសភាកម្ពុជា ជាមួយគណៈប្រតិភូមកពីវិទ្យាស្ថានវិទ្យាសាស្ត្រឥណ្ឌូនេស៊ី ក្រោមកិច្ចសម្របសម្រួលរបស់ស្ថានទូតឥណ្ឌូនេស៊ីប្រចាំប្រទេសកម្ពុជា។ សមាសភាពខាងរាជបណ្ឌិត្យសភាកម្ពុជាមានចំនួន ១២ រូប ដោយរូបរួមមាន បណ្ឌិត **គិន ភា** បណ្ឌិត **ផុន កសិកា** បណ្ឌិត **គី សេរីវឌ្ឍន៍** និងសហការី ៩រូបផ្សេងទៀត ដោយឡែកខាងភាគីឥណ្ឌូនេស៊ី មានឯកឧត្តមអគ្គរដ្ឋទូត និងមន្ត្រីស្ថានទូតចំនួន ៣ រូប ហើយខាងវិទ្យាស្ថានវិទ្យាសាស្ត្រឥណ្ឌូនេស៊ី មានសមាសភាពចំនួន ១៣រូប ដែលជាថ្នាក់ប្រធានវិទ្យាស្ថាន និងប្រធានមជ្ឈមណ្ឌល ។

ក្នុងកិច្ចប្រជុំនេះ ភាគីទាំងពីរបានបង្ហាញអំពីស្ថាប័នរបស់ខ្លួនរៀងៗខ្លួន និងបានពិភាក្សាអំពីលទ្ធភាពនៃកិច្ចសហប្រតិបត្តិការ ព្រមទាំងប្រធានបទដែលគួរសិក្សារួមគ្នា។ ក្នុងនោះ បណ្ឌិត **គិន ភា** ក៏បានលើកឡើងនូវអនុសាសន៍៩ ចំណុចដែលទទួលបានអំពីកិច្ចប្រជុំក្រុមអ្នកជំនាញកម្ពុជាឥណ្ឌូនេស៊ី កាលពីខែ កក្កដា ឆ្នាំ ២០០៧ នាពេលកន្លងមក ជូនអង្គប្រជុំ។

ឯកឧត្តមអគ្គរដ្ឋទូត ក៏ដូចជាអង្គប្រជុំទាំងមូលបានវាយតម្លៃខ្ពស់ចំពោះអនុសាសន៍ទាំង៩ចំណុចនោះ ហើយថានឹងយកទៅពិចារណាស៊ីជម្រៅ។

បន្ទាប់ពីពិភាក្សាគ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោមៈ

១. រៀបចំបញ្ជីប្រធានបទអាទិភាពដែលគួរស្រាវជ្រាវរួមគ្នា រួមមាន វិស័យនយោបាយ សេដ្ឋកិច្ច ប្រវត្តិសាស្ត្រ វប្បធម៌ អប់រំ ទេសចរ ជាដើម។

២.រៀបចំកិច្ចប្រជុំជាមួយគ្នាឱ្យបានទៀងទាត់។

៣.ចាត់ឱ្យមានអ្នកទំនាកទំនងសម្រាប់ស្ថាប័នទាំងពីរដើម្បីរក្សាទំនាក់ទំនងជាមួយគ្នា។

៤. ភាគីទាំងពីរអរគុណស្ថានទូតឥណ្ឌូនេស៊ី ដែលបានសម្របសម្រួលឱ្យមានកិច្ចប្រជុំនៅថ្ងៃនេះ។



# ឯកឧត្តមបណ្ឌិត ផុន កសិកា ចូលរួមក្នុងជំនួបជាមួយ ឯកឧត្តម H.E. Mr. Anatoly Borovik, អគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី

នៅថ្ងៃអង្គារ ទី១៩ ខែមករា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា និងលោកបណ្ឌិតសភាចារ្យបម្រុង **ឆេង វណ្ណារិទ្ធ** អនុប្រធានវិទ្យាស្ថាន បានអញ្ជើញចូលរួមក្នុងជំនួបជាមួយឯកឧត្តម Anatoly Borovik ជាអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។





# ឯកឧត្តមបណ្ឌិត ផុន កសិកា ចូលរួមក្នុងជំនួបជាមួយ ឯកឧត្តម Benjamin Wohlauer អនុប្រធានបេសកកម្មនៃស្ថានទូតសហរដ្ឋអាម៉េរិក

នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមក្នុងជំនួបជាមួយឯកឧត្តម Mr. Benjamin Wohlauer, ជាអនុប្រធានបេសកកម្មនៃស្ថានទូតសហរដ្ឋអាម៉េរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។




ជំនួបឯកឧត្តម Mr. Benjamin Wohlauer

# ឯកឧត្តមបណ្ឌិត ផុន កសិកា ចូលរួមក្នុងជំនួបជាមួយលោកជំទាវ Liurka Rodriguez Barrios, ឯកអគ្គរាជទូតនៃសាធារណរដ្ឋគុយបា

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមក្នុងជំនួបជាមួយលោកជំទាវ **Liurka Rodriguez Barrios** ជាឯកអគ្គរាជទូតនៃសាធារណរដ្ឋគុយបា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។



ជំនួបលោកស្រី Mrs.Liurka Rodriguez Barrios

# សកម្មភាពការងារ
# ក្នុងក្របខណ្ឌវិទ្យាស្ថាន

# ឯកឧត្តមបណ្ឌិត ផុន កសិកា
# ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
# ដឹកនាំប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០២១
# របស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

នៅព្រឹកថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ចាប់ពីម៉ោង ៩ ព្រឹកតទៅ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានអញ្ជើញដឹកនាំឯកឧត្តម លោក លោកស្រី បណ្ឌិត ជាជំនួយការ ជាថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់ ប្រជុំបូកសរុបការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម តាមរយៈប្រព័ន្ធអនឡាញ Google Meet ក្រោមរបៀបវារៈ៖

១-របាយការណ៍សកម្មភាពការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមសង្ខេប ឆ្នាំ២០២១
២-ការលើកផែនការការងារឆ្នាំ២០២២




Phaveng
SO
SO Suthy
j
jolie ta
Sothiary Toch
Theany Kheang
chea vanny
Sokunthea Hay
Tong Ly
Pann Vutha
S
Song Syna
T
TEPVORNEATH TU
Tieng Tieng
prosepanharith min
Vannarith Chheng
Y
9:13 AM
tyh-tzoa-fyv

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំក្រុមការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ខែតុលា

នៅរសៀលថ្ងៃអង្គារ ទី១៩ ខែតុលា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានអញ្ជើញដឹកនាំប្រជុំក្រុមការងាររៀបចំផែនការវិទ្យាស្ថាន ក្រោមរបៀបវារៈ ៖

១-ដំណើរការងារទូទៅក្នុងវិទ្យាស្ថាន

២-ការងារគម្រោងស្រាវជ្រាវឆ្នាំ២០២១

៣-ការសរសេរអត្ថបទចុះផ្សាយ (អត្ថបទឧបត្ថម្ភ ដោយ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម និង អត្ថបទរបស់ជំនួយការគម្រោង ឆ្នាំ២០២១) ការងារទស្សនាវដ្ដី ការងារកលិកបត្រ

៤-ការរៀបចំការងារប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០២១។



# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំ ការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ខែសីហា

នៅព្រឹកថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩ ព្រឹក វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានរៀបចំកិច្ចប្រជុំរួមវិទ្យាស្ថាន តាមរយៈប្រព័ន្ធ Google Meet ដែលដឹកនាំដោយឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន និងមានការចូលរួមពីឯកឧត្តមបណ្ឌិតទីប្រឹក្សាវិទ្យាស្ថាន ថ្នាក់ដឹកនាំ និង មន្ត្រីវិទ្យាស្ថានមនុស្សនិងវិទ្យាសាស្ត្រសង្គម ក្រោមរបៀបវារៈ៖

១-ដំណើរការប្រព្រឹត្តទៅរបស់វិទ្យាស្ថានលើកិច្ចការស្រាវជ្រាវ

២-ការរៀបចំទីតាំងថ្មីវិទ្យាស្ថាន នៅអគារខេមរវិទូ







tong ly កំពុងបង្ហាញ
Royal Academy of Cambodia
tong ly
Kaseka Phon
ponnarath sour
lorn nara
Theany Kheang
Tu Youkhim
15 នាក់ច្រើនទៀត
Pann Vutha បានចេញពីការប្រជុំ
មនុស្ស
បញ្ចូលមនុស្ស
Galacy A71
HEM LACH
Kang Om
Kaseka Phon
lorn nara
Meakh sary
ponnarath sour
prosepanharith min
Rii Rii Rii Rii
Sokunthea Hay
9:33 AM | vwd-bcpv-oae


tong ly កំពុងបង្ហាញ
ឆ្នាំ២០២១
tong ly
Kaseka Phon
ponnarath sour
lorn nara
Theany Kheang
Tu Youkhim
16 នាក់ច្រើនទៀត
មនុស្ស
បញ្ចូលមនុស្ស
Sokunthea Hay
Song Syna
tevy prom
Theany Kheang
tong ly
tong ly
Tu Youkhim
Vandara HAK
Yinpo Channel
ZHHANN CHHENG
9:33 AM | vwd-bcpv-oae


tong ly កំពុងបង្ហាញ
Royal Academy of Cambodia
tong ly
Kaseka Phon
ponnarath sour
lorn nara
Theany Kheang
Tu Youkhim
15 នាក់ច្រើនទៀត
Pann Vutha បានចេញពីការប្រជុំ
មនុស្ស
បញ្ចូលមនុស្ស
Galacy A71
HEM LACH
Kang Om
Kaseka Phon
lorn nara
Meakh sary
ponnarath sour
prosepanharith min
Rii Rii Rii Rii
Sokunthea Hay
9:33 AM | vwd-bcpv-oae

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំ ការងារវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ខែកក្កដា

នៅថ្ងៃព្រហស្បតិ៍ ទី៨ ខែកក្កដា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩៖០០ ព្រឹកតទៅ វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម បានរៀបចំកិច្ចប្រជុំរួមវិទ្យាស្ថាន តាមរយៈប្រព័ន្ធ Google Meet ដែលដឹកនាំដោយ ឯកឧត្តម បណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន និងមានការចូលរួមពីឯកឧត្តម បណ្ឌិតទីប្រឹក្សាវិទ្យាស្ថាន ថ្នាក់ដឹកនាំ និង មន្ត្រី វិទ្យាស្ថានមនុស្សនិងវិទ្យាសាស្ត្រសង្គម ក្រោមរបៀបវារៈ

១-ដំណើរការងារវិទ្យាស្ថានមនុស្សនិងវិទ្យាសាស្ត្រសង្គម
២-បញ្ហាផ្សេងៗ




Meet - nej-rhfc-jmo
https://meet.google.com/nej-rhfc-jmo
Kaseka Phon on display
Vannarith Chheng
chhoun savorn
Kaseka Phon
Vandara HAK
Ponnarath sour
Chea Vanny
17 នាក់ផ្សេងទៀត
Humans
Sokunthea Hay
Song Syna
tevy prom
Theany Kheang
Tieng Tieng
tong ly
Tu Youkhim
Vandara HAK
Vannarith Chheng
YAYA Konpapa
ZHHANN CHHENG
10:45 AM | Nej-rhfc-jmo
86°F Partly sunny
10:45 AM
7/8/2021


Meet - nej-rhfc-jmo
https://meet.google.com/nej-rhfc-jmo
Kaseka Phon on display
៤.២.២. ទស្សនាវដ្ដីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
តាមគោលការណ៍ដែលធ្លាប់បានប្រើប្រាស់កាលពីឆ្នាំ២០២០ កន្លងមកនេះ យើងប្រើប្រាស់ថវិកាខ្ទង់រដ្ឋទេយ្យ ដើម្បីលើកទឹកចិត្តការងារស្រាវជ្រាវ ឬរៀបចំអត្ថបទសម្រាប់បោះពុម្ពក្នុងទស្សនាវដ្ដីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម តាមគោលការណ៍ខាងក្រោម៖
ល.រ | ប្រភេទគម្រោង | ថវិកា/គម្រោង | ចំនួន | ថវិកាសរុប | ផ្សេងៗ
០១ | គម្រោងរបស់នាយកដ្ឋានចំណុះនីមួយៗ | ៣០ម៉ឺនរៀល | ៨ | ២.៤លាន | ប្រើប្រាស់ទិន្នន័យមានស្រាប់ ឬការសំយោគបណ្ណាល័យសាស្ត្រ
០២ | គម្រោង/អត្ថបទបុគ្គល | ១០ម៉ឺនរៀល | ២០ | ២លាន
សរុប | ៤.៤លាន
SO Suthy
Kaseka Phon
Ponnarath sour
Tieng Tieng
Chea Vanny
Tu Youkhim
16 នាក់ផ្សេងទៀត
Humans
SO Suthy
Song Syna
tevy prom
Theany kheang
Theany Kheang
Tieng Tieng
tong ly
Tu Youkhim
Vannarith Chheng
Yinpo Channel
ZHHANN CHHENG
9:32 AM | Nej-rhfc-jmo
84°F Partly sunny
9:32 AM
7/8/2021

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំក្រុម ការងារស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

តាមការចង្អុលបង្ហាញពីសំណាក់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ចាប់ពីម៉ោង ១៤៖៣០ តទៅ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន បានដឹកនាំអង្គប្រជុំក្រុមការងារវិទ្យាស្ថានមួយ តាមរយៈប្រព័ន្ធហ្គោហ្គលមីត ដើម្បីរៀបចំពិនិត្យលទ្ធភាពសិក្សាស្វែងយល់លើប្រធានបទ «ការស្រាវជ្រាវពីជនជាតិវៀតណាមនៅកម្ពុជា» ដោយផ្តោតជាគោលលើការរស់នៅលើផ្ទះបណ្តែតទឹកតាមដងទន្លេ មេគង្គ និងបឹងទន្លេសាប ជាដើម។



# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំក្រុម ការងារស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ចាប់ពីម៉ោង ១៤៖០០ តទៅ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន បានដឹកនាំអង្គប្រជុំក្រុមការងារស្រាវជ្រាវវិទ្យាស្ថានមួយ តាមរយៈប្រព័ន្ធហ្គោហ្គលមីត បន្តពីថ្ងៃទី១៤ ខែមិថុនា ដើម្បីបែងចែកការងារស្រាវជ្រាវលើប្រធានបទ «ការស្រាវជ្រាវពីជនជាតិវៀតណាមនៅកម្ពុជា» ដោយ ផ្តោតជាគោលលើការរស់នៅលើផ្ទះបណ្តែតទឹកតាមដងទន្លេ មេគង្គ និងបឹងទន្លេសាប ជាដើម។






# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំបូកសរុបការងារឆ្នាំ២០២០ និងលើកផែនការការងារឆ្នាំ២០២១

ថ្ងៃអង្គារ ៥រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមបានរៀបចំប្រជុំវិទ្យាស្ថាន តាមរបៀបវារៈ

-ការងារដែលបានអនុវត្តឆ្នាំ២០២០កន្លងទៅ

-គម្រោងស្រាវជ្រាវដែលទទួលបានសម្រាប់អនុវត្តក្នុងឆ្នាំ២០២១

-ផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តនៅវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម





កិច្ចប្រជុំវិទ្យាស្ថាននៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ដឹកនាំប្រជុំរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

នៅថ្ងៃអង្គារ ១២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ នៅវិទ្យាស្ថានមនុស្សនិងវិទ្យាសាស្ត្រសង្គម មានរៀបចំកិច្ចប្រជុំវិសាមញ្ញ ដឹកនាំដោយឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានដោយមានការចូលរួមពីលោក លោកស្រី បណ្ឌិត ជាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋានទាំងអស់នៃវិទ្យាស្ថាន លើរបៀបវារៈ «ផែនការយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថាន»។

ផែនការយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថាន បង្កើតឡើងស្របទៅតាមដំណើរប្រព្រឹត្តិទៅនៃរាជបណ្ឌិត្យសភាកម្ពុជា គឺពាក់ព័ន្ធនឹងការជំរុញការស្រាវជ្រាវតាមនាយកដ្ឋានជំនាញទាំងអស់ដែលស្ថិតនៅក្រោមវិទ្យាស្ថាន និងមន្ត្រីជំនាញឱ្យបង្កើនការស្រាវជ្រាវសម្រាប់ផលិតជាស្នាដៃបោះពុម្ពផ្សាយ និង ផ្សព្វផ្សាយតាមប្រព័ន្ធសង្គម (គេហទំព័រ និង ហ្វេសប៊ុក)។

អង្គប្រជុំក៏បានសម្រេចបង្កើតផែនដោយកំណត់ថា សកម្មភាពនិងស្នាដៃស្រាវជ្រាវដែលនាយកដ្ឋាន និងមន្ត្រីស្រាវជ្រាវផលិតបាននឹងត្រូវផ្សព្វផ្សាយនៅក្នុងព្រឹត្តិបត្រ (ព្រឹត្តិបត្រមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម), ទស្សនាវដ្ដី (ទស្សនាវដ្ដីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម) និង កាលិកបត្រ (កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម) និងផលិតកម្មវីដេអូឯកសារ (វីដេអូវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម)។




កិច្ចប្រជុំ «ផែនការយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថាន» ជាមួយជាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន

# ការរៀបចំការិយាល័យថ្មីនៃវិទ្យាស្ថាន
# មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៅអគារខេមរវិទូ

អនុវត្តតាមការណែនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា នៅខែកក្កដា ឆ្នាំ២០២១ ថ្នាក់ដឹកនាំនិងមន្ត្រី វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ទាំងអស់បានរៀបចំរើសម្ភារៈការិយាល័យការងាររបស់ខ្លួន និងនាយកដ្ឋាននីមួយៗ មកតាំងទីនៅសាលវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ជ្រុងនិរតី ជាន់ទី២ អគារខេមរវិទូ តាមការកំណត់របស់រាជបណ្ឌិត្យសភាកម្ពុជា និងបែងចែកប្លង់នាយកដ្ឋានរបស់វិទ្យាស្ថាន តាមប្លង់មេ ក្រោមការបែងចែក និងសម្របសម្រួលទីតាំងនាយកដ្ឋានពីសំណាក់ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន។




ជាមួយគ្នានេះ ដើម្បីបង្កើនបរិយាកាសល្អ ក្នុងពេលបំពេញការងារ ក៏ដូចជា ថែរក្សាបរិស្ថានល្អ នៅក្នុងវិទ្យាស្ថាន ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន បានដឹកនាំមន្ត្រីមួយចំនួន ជាអាទិ៍ លោក **សួ ប៉ុណ្ណារ៉ាត់** លោក **យិន ពោ** រៀបចំគំនូរ រូបថត លម្អតាមផ្ទៃជញ្ជាំង រៀបចំថូផ្កាដាក់លើតុ ការិយាល័យរបស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់ ក្នុងវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ព្រមទាំងរៀបចំផើងផ្កាលម្អទីធ្លាខាងមុខវិទ្យាស្ថានបង្កើត បានជាបរិយាកាសបៃតង ត្រជាក់ភ្នែកសម្រាប់បន្ធូរ ភាពតានតឹងក្នុងពេលបំពេញការងារផងដែរ។




# កិច្ចប្រជុំនិងការងារក្នុងក្រុមខណ្ឌ
# រាជបណ្ឌិត្យសភាកម្ពុជា

# ឯកឧត្តមបណ្ឌិត ផុន កសិកា ចូលរួមសន្និសីទអន្តរជាតិលើកទី១៦ ស្តីពី បរិបទថ្មី នៃទំនាក់ទំនងអាស៊ាន-កូរ៉េ

នៅថ្ងៃទី១៦-១៧ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម បានដឹកនាំលោក លោកស្រី បណ្ឌិត ជាអនុប្រធានវិទ្យាស្ថាន ប្រធាននាយកដ្ឋាន និង តំណាងនាយកដ្ឋានទាំង៩ បានចូលរួមសន្និសីទអន្តរជាតិលើកទី១៦ ស្តីពី បរិបទថ្មី នៃទំនាក់ទំនងអាស៊ាន-កូរ៉េ រៀបចំឡើងដោយមជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា សហការឧបត្ថម្ភដោយមជ្ឈមណ្ឌល ជ័យ សម្រាប់ការសិក្សាជាន់ខ្ពស់ នៃសាធារណរដ្ឋកូរ៉េ នៅសាលសន្និសីទជាន់ផ្ទាល់ដី អគារខេមរវិទូ របសក ចាប់ពីម៉ោង ៨៖០០ ព្រឹក ថ្ងៃទី១៦-១៧ ធ្នូ ២០២១ ៖

១- ឯកឧត្តមបណ្ឌិត **ផុន កសិកា**
២- លោកបណ្ឌិត **ឆេង វណ្ណារិទ្ធ**
៣- លោកស្រីបណ្ឌិត **ព្រុំ ទេវី** ចូលរួមជាវាគ្មិន
៤- ឯកឧត្តមបណ្ឌិត **អ៊ុំ ប៉ុម**
៥- លោក **ឃិន យ៉ង់**
៦- លោក **មាឃ សារី**
៧- លោកស្រីបណ្ឌិត **ជា វណ្ណី**
៨- លោកបណ្ឌិត **ហាក់ វ៉ាន់ដារា**
៩- លោកបណ្ឌិត **ឈឿន សារេន**
១០- លោក **សួ ប៉ុណ្ណារ៉ាត់**
១១- លោក **ហៃ សុគន្ធា**
១២- លោកបណ្ឌិត **ហែម ឡាច**
១៣- លោកបណ្ឌិត **ប៉ាន់ វុត្ថា**។




16th Annual International Conference on
"The New Context of ASEAN-Korea Relations"
December 16-17, 2021


16th Annual International Conference on
"The New Context of ASEAN-Korea Relations"
December 16-17, 2021
Co-Organized by :

# ឯកឧត្តមបណ្ឌិត ផុន កសិកា ចូលរួមសន្និសីទអន្តរជាតិ ស្តីពី តួនាទីរបស់ចិនក្នុងសតវត្សទី២១ និងទំនាក់ទំនងរបស់ចិនជាមួយអាស៊ាន

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានដឹកនាំលោក លោកស្រី បណ្ឌិត ជាប្រធាននាយកដ្ឋាន មន្ត្រីជំនាញ អញ្ជើញចូលរួមក្នុងសន្និសីទអន្តរជាតិ ស្តីពី «តួនាទីរបស់ចិនក្នុងសតវត្សរ៍ទី២១ និងទំនាក់ទំនងរបស់ចិនជាមួយអាស៊ាន» ដែលបានប្រព្រឹត្ត ទៅនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ នៅសាលមរតកសិល្បៈខ្មែរ ជាន់ទី៤ អគារតេជោ្ររទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា និងតាមរយៈប្រព័ន្ធ Zoom meeting ៖

១- ឯកឧត្តមបណ្ឌិត **ផុន កសិកា** ចូលរួមដោយផ្ទាល់
២- លោកបណ្ឌិត **ឈឿន សាវន**
៣- លោក **សួ ប៉ុណ្ណារ៉ាត់** ចូលរួមដោយផ្ទាល់
៤- លោកបណ្ឌិត **ហែម ឡាច**
៥- លោកបណ្ឌិត **ទុយ យូឃីម**
៦- លោក **យិន ពោ** ចូលរួមដោយផ្ទាល់
៧- លោកបណ្ឌិត **សុង ស៊ីណា**
៨- លោក **សាន ចេង** ចូលរួមដោយផ្ទាល់។

# ឯកឧត្តមបណ្ឌិត ផុន កសិកា ចូលរួមសន្និសីទអន្តរជាតិ
# ស្តីពី យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក និងការទូតរបស់រដ្ឋតូចៗ

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានដឹកនាំលោក លោកស្រី បណ្ឌិត ជាប្រធាននាយកដ្ឋាន មន្ត្រីជំនាញ មានលោក **សួ ប៉ុណ្ណារ៉ាត់** ប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ លោកបណ្ឌិត **ហែម ឡាច** តំណាង នាយកដ្ឋាននីតិសាស្ត្រ លោកបណ្ឌិត **ទុយ យូឃីម** អនុប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ លោកបណ្ឌិត **សុង ស៊ីណា** អនុប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ ចូលរួម វេទិកាទំនាក់ទំនងអន្តរជាតិ ស្តីពី **«យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកនិងការទូតរបស់រដ្ឋតូចៗ»** នៅសាលមរតកសិល្បៈខ្មែរ តាមរយៈប្រព័ន្ធ Zoom meeting ។






# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម អញ្ជើញចូលរួមពិធីសូត្រមន្ត អគារខេមរវិទូ

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ ម៉ោង ២៖៣០ រសៀល រាជបណ្ឌិត្យសភាកម្ពុជា បានប្រារព្ធពិធីសូត្រមន្តនៅអគារខេមរវិទូ ដើម្បីសុំពរជ័យសិរី សួស្តី ជ័យមង្គល ប្រោះព្រំដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជបណ្ឌិត្យសភាកម្ពុជាទាំងអស់ ដែលផ្លាស់ប្តូរទីតាំងការិយាល័យការងាររបស់ខ្លួនពីអគារចាស់ មកកាន់អគារខេមរវិទូនេះ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាបណ្ឌិតសភាចារ្យ បណ្ឌិត្យសភាចារ្យបម្រុង ថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជា និងថ្នាក់ដឹកនាំវិទ្យាស្ថាន មជ្ឈមណ្ឌលឧបសម្ព័ន្ធ។ ពិធីសូត្រមន្តទីតាំងការងារថ្មីនេះប្រព្រឹត្តឡើងតាមប្រពៃណីបែបព្រះពុទ្ធសាសនា ដោយបាននិមន្ត ព្រះសុមេធវង្ស បណ្ឌិត **សុខ ប៊ុនធឿន** ព្រះរាជាគណៈថ្នាក់ទោ ជាព្រះចៅអធិការវត្តនន្ទមុនី មកស្វាធ្យាយជយន្តោ និងលោកតាអាចារ្យមករៀបចំកម្មវិធីតាមលំអានប្រពៃណីពីបុរាណរៀងមក។ ក្នុងឱកាសដ៏មង្គលនេះ ថ្នាក់ដឹកនាំវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចាប់ពីថ្នាក់នាយកដ្ឋានឡើង ដឹកនាំដោយឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ចូលរួមពិធីសូត្រមន្តអគារខេមរវិទូ។ កម្មវិធីសូត្រមន្តនេះ ប្រព្រឹត្តឡើងដោយប្រកាន់ខ្ជាប់គោលការណ៍សុខាភិបាល ស្មារតី បីកុំ និងបីការពារជានិច្ច ដើម្បីរក្សាសុវត្ថិភាពសុខភាពអ្នកចូលរួមទាំងអស់គ្នា។



# ឯកឧត្តមបណ្ឌិត ផុន កសិកា
# ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
# ចូលរួមកិច្ចប្រជុំស្តីពីដំណើរការប្រព្រឹត្តទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា

នៅថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព .ស.២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម និងលោក **ឃិន យ៉ង់** មន្ត្រីទទួលបន្ទុកនាយកដ្ឋានកិច្ចការទូទៅ បានចូលរួមកិច្ចប្រជុំស្តីពីដំណើរការប្រព្រឹត្តទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា។

ឯកឧត្តមបណ្ឌិត **យង់ ពៅ** អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា អញ្ជើញជាតំណាងរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជាដឹកនាំកិច្ចប្រជុំនេះ បានលើកពីការពង្រឹងនិងបង្កើនការសរសេរអត្ថបទស្រាវជ្រាវដោយមន្ត្រីម្នាក់ៗត្រូវធ្វើរបាយការណ៍ស្រាវជ្រាវជាប្រចាំ។ មិនមែនតែមន្ត្រីស្រាវជ្រាវទេ ប្រធានវិទ្យាស្ថាន និងប្រធាននាយកដ្ឋានជំនាញទាំងអស់ ត្រូវសរសេរអត្ថបទស្រាវជ្រាវតាមជំនាញផងដែរ។ ក្នុងកិច្ចការស្រាវជ្រាវនេះមានការសរសេរអត្ថបទស្រាវជ្រាវដោយផ្អែកលើឯកសារមានស្រាប់ (Secondary Data Research) ឬក៏បកប្រែអត្ថបទតាមជំនាញពីភាសាបរទេសមកជាភាសាខ្មែរ។




កិច្ចប្រជុំស្តីពីដំណើរការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជានៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១

# ឯកឧត្តមបណ្ឌិត ផុន កសិកា
# ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំនៃរាជបណ្ឌិត្យសភាកម្ពុជា ស្តីពី
# «ដំណើរវិវត្តន៍ស្ថានភាពនយោបាយក្នុងប្រទេសមីយ៉ាន់ម៉ា»

នៅថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព .ស.២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានអញ្ជើញចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំនៃរាជបណ្ឌិត្យសភាកម្ពុជា ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ស្តីពី **«ដំណើរវិវត្តន៍ស្ថានភាពនយោបាយក្នុងប្រទេសមីយ៉ាន់ម៉ា»**។






កិច្ចប្រជុំក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច

# ឯកឧត្តមបណ្ឌិត ផុន កសិកា
# អញ្ជើញចុះអនុស្សារណៈយោគយល់គ្នារវាង
# «វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
# និងវិទ្យាស្ថានបេតិកភណ្ឌវប្បធម៌នៃសាកលវិទ្យាល័យវ៉ាសេដា,

នារសៀលថ្ងៃសុក្រ ទី១៩ ខែកុម្ភៈ ឆ្នាំ ២០២១ រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំកម្មវិធី ចុះអនុស្សារណៈយោគយល់គ្នារវាង «វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា និងវិទ្យាស្ថានបេតិកភណ្ឌវប្បធម៌នៃសាកលវិទ្យាល័យវ៉ាសេដា ប្រទេសជប៉ុន» ក្រោមអធិបតីភាពឯកឧត្តម **សូត្រ សំណាង** អគ្គលេខាធិការរងនៃរាជបណ្ឌិតសភាកម្ពុជា ជាតំណាងឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដោយធ្វើការចុះហត្ថលេខាក្នុងកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់គ្នារវាងវិទ្យាស្ថានទាំងពីរ ដោយឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា និងលោកសាស្ត្រាចារ្យបណ្ឌិត Yukitsugu Tabata នាយកវិទ្យាស្ថានបេតិកភណ្ឌវប្បធម៌ នៃសាកលវិទ្យាល័យវ៉ាសេដា ប្រទេសជប៉ុន ក្នុងគោលបំណងព្រមព្រៀងធ្វើកិច្ចសហប្រត្តិបត្តិការជាមួយគ្នាក្នុងកម្មវិធីអន្តរជាតិពាក់ព័ន្ធនានា ដោយផ្អែកលើគោលការណ៍ផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក ត្បិតស្ថាប័នទាំងពីរមានទិសដៅរួមគ្នា រួមមានក្នុងវិស័យសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ, គ្រប់គ្រងបេតិកភណ្ឌ, ជាតិពន្ធុវិទ្យា ជាដើម...។




ទិដ្ឋភាពចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិតសភាកម្ពុជា និង វិទ្យាស្ថានបេតិកភណ្ឌវប្បធម៌ នៃសាកលវិទ្យាល័យវ៉ាសេដា ប្រទេសជប៉ុន

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមប្រជុំក្នុងជំនួប ជាមួយឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំប្រទេសកម្ពុជា

នៅថ្ងៃទី២២ កុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ចូលរួមប្រជុំជាមួយឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំប្រទេសកម្ពុជា នៅសាលប្រជុំអគារតេជោសែនទេវី ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។




ជំនួបឯកអគ្គរដ្ឋទូតចក្រភពអង់គ្លេស

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមប្រជុំ Brainstorm

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមចូលរួមប្រជុំ Brainstorm មុនជំនួបជាមួយភាគី NRC នៃសាធារណរដ្ឋកូរ៉េ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅបន្ទប់ស្លឹករឹត វេលាម៉ោង ៤.០០ នាទីរសៀល ស្តីពី **«កម្ពុជានិងកូរ៉េឯកភាពលើការស្រាវជ្រាវយុទ្ធសាស្ត្រនិងគោលនយោបាយជាតិរួមគ្នា»** ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។






ប្រជុំ Brainstorm មុនជំនួបភាគី NRC នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

# លោកស្រីបណ្ឌិតសភាចារ្យបម្រុង ព្រុំ ទេវី ចូលរួមប្រជុំ
# ប្រធាន-អនុប្រធានក្រុមបច្ចេកសព្ទនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

នៅព្រឹកថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ លោកស្រីបណ្ឌិតសភាចារ្យបម្រុង **ព្រុំ ទេវី** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានចូលរួមប្រជុំប្រធាន-អនុប្រធានក្រុមបច្ចេកសព្ទនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ តាមរយៈប្រព័ន្ធហ្សូម។



# ថ្នាក់ដឹកនាំនិងមន្ត្រី វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមផ្ដល់បទសម្ភាសន៍ដល់ក្រុមការងារបច្ចេកទេស រៀបចំផែនការយុទ្ធសាស្ត្ររាជបណ្ឌិត្យសភាកម្ពុជា

នៅក្នុងខែកញ្ញា ឆ្នាំ២០២១ ថ្នាក់ដឹកនាំនិងមន្ត្រី វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម តាមចំនួនកំណត់ បានចូលរួមផ្ដល់បទសម្ភាសន៍ដល់ក្រុមការងារបច្ចេកទេស នៃលេខាធិការដ្ឋានក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្ររាជបណ្ឌិត្យសភាកម្ពុជា ដែលបានចុះសម្ភាសន៍ប្រមូលទិន្នន័យតាមកម្មវិធី និងសមាសភាពដែលត្រូវសម្ភាសន៍ដូចមានក្នុងតារាងជូនភ្ជាប់ តាមពេលវេលាដែលបានរៀបចំ។



# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ចូលរួម កិច្ចពិភាក្សាតុមូល ស្តីពី សារៈសំខាន់នៃការស្រាវជ្រាវ

នាថ្ងៃសុក្រ ទី២៩ ខែមករា ឆ្នាំ២០២១ ចាប់ពីម៉ោង ៨៖៣០ ព្រឹក នាសាលមរតកសិល្បៈខ្មែរ ជាន់ទី៤ អគារតេន្រ្ទទេវី ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានដឹកនាំថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថាន អញ្ជើញចូលរួមកិច្ចពិភាក្សាតុមូល ស្តីពី **សារៈសំខាន់នៃការស្រាវជ្រាវ** ដែលរៀបចំឡើងដោយ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា។ សមាសភាពចូលរួមនាពេលនោះមាន៖

១~លោកស្រីបណ្ឌិត **ជា វណ្ណី** ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និងយែនឌ័រ

២~លោកបណ្ឌិត **សូ សុធីរ** មន្ត្រីស្រាវជ្រាវជាន់ខ្ពស់ នាយកដ្ឋានវិទ្យាសាស្ត្រអប់រំ

៣~លោក **ឃិន ពោ** អនុប្រធាននាយកដ្ឋាននីតិសាស្ត្រ

៤~លោកបណ្ឌិត **ប៉ាន់ វុត្ថា** តំណាងនាយកដ្ឋានទស្សនវិជ្ជា និងសង្គមវិទ្យា

៥~លោកបណ្ឌិត **ក្លាន់ ធុល** មន្ត្រីស្រាវជ្រាវជាន់ខ្ពស់នាយកដ្ឋានទស្សនវិជ្ជា និងសង្គមវិទ្យា។

# លោក ហៃ សុគន្ធា
# ចូលរួមក្នុងគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍

លោក **ហៃ សុគន្ធា** មន្ត្រីតំណាងនាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម បានចូលរួមប្រជុំ និងពិភាក្សាកិច្ចការជាមួយក្រុមការងារ TVET បានប្រព្រឹត្តដូចខាងក្រោម ៖

-ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ តាមប្រព័ន្ធហ្ស៊ូម ដឹកនាំដោយ ឯកឧត្តម **សូត្រ សំណាង** ប្រធានគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ដើម្បីកែសម្រួលកម្មវិធីសិក្សា មុខវិជ្ជា "ផុងកាហ្វេនិងក្រឡុកស្រា"

-ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ តាមប្រព័ន្ធតេឡេក្រាម ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត្យសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ក្រោមប្រធានបទ **"ទស្សនវិជ្ជានិងចក្ខុវិស័យនៃការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍នៅរាជបណ្ឌិត្យសភាកម្ពុជា"** ដើម្បីស្វែងរកជាតុចូលនៃ ការថតផ្សព្វផ្សាយ

-ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រុមការងារដឹកនាំដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ក្នុងរៀបចំថតសកម្មភាពនានា សម្រាប់ផលិតជាវីដេអូ និងរូបភាពនានា ដើម្បីផ្សព្វផ្សាយអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅអគារស៊ី "Building C"

-ថ្ងៃទី២ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធហ្ស៊ូម ក្រោមអធិបតីភាពរបស់ឯកឧត្តម **សូត្រ សំណាង** ប្រធានក្រុមការងារគម្រោង និងជាអគ្គលេខាធិការរងនៃរាជបណ្ឌិត្យសភាកម្ពុជា

-ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធហ្ស៊ូម ក្រោមអធិបតីភាពរបស់ លោក **ហេង សុភី** អនុប្រធានក្រុមការងារគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍

-ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ នៅបន្ទប់បណ្តុះបណ្តាលភេសជ្ជៈអគារស៊ី(Beverage Training Room-Building C) ក្រោមអធិបតីភាពរបស់ លោក **សាន សុវានិត** ប្រធានស្តីទី មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា

-ចូលរួមប្រជុំនិងពិភាក្សាកិច្ចការជាមួយក្រុមការងារគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ តាមប្រព័ន្ធហ្ស៊ូម ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៩.០០ ដល់ ១១.០០ព្រឹក ក្រោមអធិបតីរបស់ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានរាជបណ្ឌិត្យសភាកម្ពុជា

តាមហ្សូមថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ 




សកម្មភាពថត ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១



កិច្ចពិភាក្សាដើម្បីជាមូលដ្ឋាននៃការថតដើម្បីផ្សព្វផ្សាយ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១



-នៅថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០២១ វេលាម៉ោង ១០៖០០ ព្រឹក លោក **ហៃ សុគន្ធា** ជាសមាជិកក្រុមការងារបណ្តុះបណ្តាលវិជ្ជាជីវីបានចូលរួមពិនិត្យទីតាំងផ្ទាល់នៃបន្ទប់បង្រៀនផ្នែកកាហ្វេ និងក្រឡុកស្រា ធ្វើឈីស និង ផ្ទះបាយ ព្រមទាំងទីធ្លាជុំវិញ ដើម្បីពន្លឿនការងារ និងលើកជាគំនិតបន្ថែម។ បន្ទាប់មក ក្រុមការងារបានជួបប្រជុំដើម្បីពិភាក្សាលម្អិតលើចំនុចមួយចំនួន៖

១ រំលឹកអំពីការចុះកិច្ចសន្យាការងាររវាងបេសក និងលោកចុងភៅ **ស៊ រ សំអាង**

២ ពិនិត្យលើតារាងតម្លៃប្រៀបធៀប

៣ ផ្សេងៗ

ជាលទ្ធផលនៃកិច្ចប្រជុំ កិច្ចការមួយចំនួនបានដាក់ចេញជូនសមាជិកក្រុមការងារទទួលខុសត្រូវ៖

-ស្នើព្រីនឯកសារបកប្រែមុខម្ហូបដែលបានបកប្រែ ដើម្បីពិនិត្យជារួម ត្រៀមជូនឯកឧត្តមបណ្ឌិតសភាចារ្យប្រធានឆ្លងសម្រេច

-ស្នើពិនិត្យតម្លៃសិក្សា ៧៥០ ដុល្លា/ម្នាក់ (ករណីសិស្ស ១២នាក់/ថ្នាក់)

-ស្នើត្រៀមផលិតវីដេអូឃ្លីប ថតមុខម្ហូប និងរៀបចំប៉ុស្តស្ដឺ

-ស្នើពន្លឿនការរៀបចំសោភណ្ឌភាព និងអនាម័យបន្ទប់អនុវត្ត (LAB)

-ស្នើសមាជិកទទួលខុសត្រូវផ្នែកបង្រៀនកាហ្វេ និងក្រឡុកស្រាជួបជាមួយគ្រូបង្គោល សិក្សាលើរយៈពេល សិក្សាចំនួនមុខកាហ្វេ និងស្រាដែលត្រូវរៀន សិក្សាតម្លៃថ្លៃដើម និងចំនួនសិស្សក្នុងមួយវគ្គ។

សូមបញ្ជាក់ថា ក្រោយពីកិច្ចប្រជុំក្រុមការងារក៏បានជួបផ្ទាល់ជាមួយលោកគ្រូបង្គោលផ្នែកកាហ្វេ និងក្រឡុកស្រា ដើម្បីពិនិត្យទីតាំងផ្ទាល់និងពិភាក្សាបន្ថែមលើលកិច្ចការចំពោះមុខ។

កិច្ចប្រជុំបានបញ្ចប់នាវេលាម៉ោង ១១៖៣០ នាទី ថ្ងៃខែឆ្នាំដដែល។



នៅថ្ងៃទី ២០ កញ្ញា ឆ្នាំ ២០២១ វេលាម៉ោង ៣ រសៀល លោក ហៃ សុគន្ធា ជាសមាជិកក្រុមការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈបានជួបប្រជុំការងារ ពិនិត្យ និងកែសម្រួលសេចក្ដីព្រាង ច្បាប់កិច្ចសន្យាការងាររវាងរបេសក និងអ្នកសម្របសម្រួលការបណ្ដុះបណ្ដាលចុងភៅ។ ជាលទ្ធផល សេចក្ដីព្រាងបានត្រូវកែសម្រួលរួចរាល់ និងព្រាងដាក់ឆ្លងយោបល់ឯកឧត្ដមប្រធានជាបន្ត។ កិច្ចប្រជុំបានបញ្ចប់នាវេលាម៉ោង ៦ ល្ងាច ថ្ងៃខែឆ្នាំដដែល។




នៅរសៀលថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ លោក ហៃ សុគន្ធា ជាសមាជិកក្រុមការងារ បានចូលរួមប្រជុំក្រុមការងារ RAC-TVET។



នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ លោក ហៃ សុគន្ធា មន្ត្រីទទួលបន្ទុកនាយកដ្ឋានភូមិវិទ្យា និង នគរូបនីយកម្ម បានចូលប្រជុំក្រុមការងារ TVET នៃរាជបណ្ឌិត្យសភាកម្ពុជា។






# លោក ហៃ សុគន្ធា ចូលរួមពិភាក្សាកិច្ចការ ជាមួយ ក្រុមការងារគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍

លោក **ហៃ សុគន្ធា** មន្ត្រីទទួលបន្ទុកនាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម បានចូលរួមពិភាក្សាកិច្ចការ ជាមួយក្រុមការងារគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ តាមប្រព័ន្ធហ្ស៊ូម ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ៩.០០ ដល់ ១០.៣០ ព្រឹក។



# លោកស្រីបណ្ឌិត ជា វណ្ណី ចូលរួមធ្វើជាវាគ្មិន
# ស្តីពី ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ

លោកស្រីបណ្ឌិត **ជា វណ្ណី** ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និងយែនឌ័រ បានចូលរួមធ្វើជាវាគ្មិន ស្តីពី **ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ** ដល់គ្រូបង្រៀនជាជនជាតិចិន ដែលបានមកបង្រៀនភាសាចិន នៅវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ វេលាម៉ោង៩ព្រឹក តាមរយៈប្រព័ន្ធវីដេអូខន់ហ្វឺរេន។



# ការចូលរួមកែលម្អបរិស្ថានធម្មជាតិនៅរាជបណ្ឌិត្យសភាកម្ពុជា របស់មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

នៅរសៀលថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ នៅសួនច្បារខាងក្រោយអគារខេមរវិទូ នៃរាជបណ្ឌិត្យសភាកម្ពុជា ថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំដាំកូនឈើ រុក្ខជាតិ និងផ្កាមួយចំនួនដែល មានដុះនៅតាមទឹកដីតំបន់នានា ផ្សេងៗពីគ្នា ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាលម្អសោភ័ណភាពទីធ្លាផង និងរួមចំណែកក្នុងកិច្ចការថែរក្សាបរិស្ថានក្នុងអង្គភាពផង។




ក្នុងឱកាសនោះផងដែរ មន្ត្រីវិទ្យាស្ថាន មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដែលមានលោក **ឃិន យ៉ង់** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និង លោក **សួ ប៉ុណ្ណារ៉ាត់** ប្រធាននាយកដ្ឋានប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រនយោបាយ ក៏បានចូលរួមដាំកូនឈើ ដាំផ្កា ដាំស្មៅ លម្អបរិស្ថាន នៅលើសួនជុំវិញអគារខេមរវិទូ ក្រោមការដឹកនាំពីសំណាក់ឯកឧត្តមបណ្ឌិត **យង់ ពៅ** អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា។




នៅរសៀលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ សមាជិកនៃវិទ្យាស្ថានមនុស្សនិងវិទ្យាសាស្ត្រសង្គម រួមមាន លោក **ឃិន យ៉ង់** លោក **សួ ប៊ុណ្ណារ៉ាត់** និងលោក **ឃិន ពោ** បានចូលរួមដាំស្មៅ និង ដាំផ្កាត្រថុក នៅក្នុងបរិវេណរាជបណ្ឌិត្យសភាកម្ពុជា ពិសេសនៅទីធ្លាសួនខាងមុខអគារខេមរវិទូ ក្នុងគោលបំណងរក្សាបរិស្ថាន និង បង្កើនសោភណ្ឌភាពក្នុងរាជបណ្ឌិត្យសភាកម្ពុជា ដែលជាការិយាល័យបំពេញការងារប្រចាំថ្ងៃ។





ការិយាល័យបំពេញការងារប្រៀបបាននឹងគេហដ្ឋានទី២ ដែលគួរថែទាំ និងរក្សាសម្រស់ឱ្យល្អស្រស់ស្អាតជានិច្ច សម្រាប់ជិវិតស្រស់ស្រាយក្នុងពេលបំពេញការងារ។

# ការចោរស្រាចប្លាច

# ការអនុវត្តគម្រោងស្រាវជ្រាវ «សរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា»

ដោយមានការណែនាំជាប្រចាំពីសំណាក់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ជាប្រធានលេខាធិការដ្ឋានគម្រោងសរសេរសៀវភៅ **«ប្រវត្តិសាស្ត្រប្រទេសកម្ពុជា»** របស់រាជបណ្ឌិត្យសភាកម្ពុជា និងសហការី បានសហការរួមចំណែកជាមួយក្រុមស្រាវជ្រាវសរសេរតាមសម័យកាលក្នុងការជំរុញដំណើរការស្រាវជ្រាវសរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

ក្នុងនាមជាលេខាធិការដ្ឋាននៃគម្រោង យើងបានរៀបចំឱ្យសមាជិកនៃគម្រោងដែលស្ថិតនៅក្នុងសម័យកាលទាំង៥ គឺ សម័យបុរេប្រវត្តិសាស្ត្រ, សម័យមុនអង្គរ, សម័យអង្គរ, សម័យក្រោយអង្គរ និងសម័យទំនើប រៀបចំប្រជុំក្រុមឱ្យបានទៀងទាត់ ដើម្បីពិភាក្សាគ្នាតាមក្រុមសម័យកាលឱ្យបានល្អិតល្អន់។

លេខាធិការដ្ឋានបានរៀបចំសំណើសុំចុះបេសកកម្មសម្រាប់ក្រុមតាមសម័យកាលនីមួយៗ នៅក្នុងខែមករា កុម្ភៈ មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា និងខែធ្នូ។

ក្នុងនាមជាលេខាធិការដ្ឋាននៃគម្រោង យើងបានរៀបចំឱ្យសមាជិកនៃគម្រោងដែលស្ថិតនៅក្នុងសម័យកាលទាំង៥ គឺ សម័យបុរេប្រវត្តិសាស្ត្រ, សម័យមុនអង្គរ, សម័យអង្គរ, សម័យក្រោយអង្គរ និងសម័យទំនើប រៀបចំប្រជុំក្រុមឱ្យបានទៀងទាត់ ដើម្បីពិភាក្សាគ្នាតាមក្រុមសម័យកាលឱ្យបានល្អិតល្អន់។

លេខាធិការដ្ឋានបានសហការជាមួយក្រុមសម័យកាលទាំង៥ រៀបចំសរុបលទ្ធផលស្រាវជ្រាវប្រចាំឆ្នាំ ជាក់ជូនឯកឧត្តមបណ្ឌិតសភាចារ្យប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងជាប្រធានគម្រោង ដើម្បីពិនិត្យ និង មានអនុសាសន៍ណែនាំ។ ជាមួយគ្នានេះដែរ ក្រោមការណែនាំចង្អុលបង្ហាញពីឯកឧត្តមបណ្ឌិតសភាចារ្យប្រធានក្រុមការងារលេខាធិការដ្ឋាន បានរៀបចំឯកសារទូទាត់ថវិកាឆ្នាំ២០២១ ជូននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

នៅថ្ងៃចន្ទ ១២រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ចាប់ពីម៉ោង ៩៖០០នាទីព្រឹក តទៅ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានលេខាធិការដ្ឋាន ក្រុមការងារគម្រោងស្រាវជ្រាវសរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានដឹកនាំកម្មវិធីប្រជុំប្រធានក្រុមការងារសរសេរប្រវត្តិសាស្ត្រតាមសម័យកាលទាំងប្រាំ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកប្រធានក្រុមការងារតាមសម័យកាល និងមន្ត្រីលេខាធិការដ្ឋាន តាមរយៈប្រព័ន្ធប្រជុំពីចម្ងាយ ហ្គោហ្គលមីត (Google Meet)។ ឯកឧត្តមបណ្ឌិត **ផុន កសិកា** បានបង្ហាញជូនអង្គប្រជុំពីការរចនាអត្ថបទ ដែលបានប្រជុំកំណត់ ដែលមាន page setup font size ជាដើម ដើម្បីរៀបចំអត្ថបទមុនប្រគល់ដល់អ្នករចនាសៀវភៅបោះពុម្ព។ អង្គប្រជុំបានពិភាក្សាលើការបែងចែកអត្ថបទតាម ទំហំ។ អង្គប្រជុំបានឯកភាពរៀបចំជារបាយការណ៍ការងារតាមដំណាក់កាល ជាពង្រាងមាតិកា និងបញ្ចូលខ្លឹមសារ ដែលរកបានទៅតាមជំពូកនីមួយៗ និងបញ្ជូនចូលក្រុមធំ ដើម្បីជូនជារបាយការណ៍ និងពិនិត្យរួមគ្នា។


Meet - nej-rhfc-jmo
https://meet.google.com/nej-rhfc-jmo
Kaseka Phon កំពុងបង្ហាញ
របៀបវារៈទី១
ទំហំសៀវភៅ៖ ទទឹង១៨ ស.ម និង បណ្ដោយ ២៥ ស.ម
Fonts: អក្សរអត្ថបទ Khmer OS Metal Chrieng, ទំហំ៖ ១១
ចំណងជើងធំ៖ Khmer OS Muol Light, ទំហំ៖ ១២ (នឹងប្រែប្រួលតាមអ្នករចនាសៀវភៅ)
ចំណងជើងតូច៖ Khmer OS Muol Light, ទំហំ៖ ១១ (នឹងប្រែប្រួលតាមអ្នករចនាសៀវភៅ)
Page setup: ទុកឱ្យអ្នករចនាសៀវភៅ
A4
Bottom: 2.54 cm, Top: 2.54 cm
menghong chhum
Kaseka Phon
Chan Dary Chou
Vanna L.
Bunny CHAN
Vong Sotheara
Sakda Taketh
អ្នក
9:49 AM | nej-rhfc-jmo
89°F Light rain
9:49 AM
6/21/2021


Meet - nej-rhfc-jmo
meet.google.com/nej-rhfc-jmo
9:28 AM
You
Vong Sotheara
Bunny CHAN
Khin Yang
Vanna L.
Sakda Taketh
Chan Dary Chou
menghong chhum
Meeting details
Turn on captions
Present now
Search the web and Windows
ENG
09:28 AM
21-Jun-2021

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានលេខាធិការដ្ឋានគម្រោង សរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា រៀបចំកិច្ចប្រជុំ ពិភាក្សាស្តីពី ការសម្រេចមាតិកាតាមក្រុមសម័យកាលនីមួយៗ

នាព្រឹកថ្ងៃពុធ ទី១០ ខែកុម្ភៈ ឆ្នាំ២០២១៖ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានលេខាធិការដ្ឋានគម្រោង តំណាងឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងជាប្រធានគម្រោង បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពី ការសម្រេចមាតិកាតាមក្រុមសម័យកាលនីមួយៗ ដោយមានការចូលរួមពីឯកឧត្តមបណ្ឌិត និងលោកបណ្ឌិត ជាប្រធានក្រុមសម័យកាលនីមួយៗនៃ **«ក្រុមអ្នកសរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា»**។ ក្នុងកិច្ចប្រជុំបានបញ្ចេញមតិយោបល់ច្រើនទៅវិញទៅមក និងបានយល់ស្របលើចំណុច មួយចំនួន តែយ៉ាងណានឹងមានរៀបចំប្រជុំនៅលើកក្រោយទៀតដើម្បីសម្រេចជាស្ថាពរ។ លោក **ឃិន យ៉ង់** សមាជិកលេខាធិការដ្ឋានគម្រោង បានចូលរួមប្រជុំនេះ។




កិច្ចប្រជុំគម្រោង «សរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជា» នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១

# លោកបណ្ឌិត វង់ សុជាវ៉ា ប្រធានក្រុមសម័យអង្គរ ដឹកនាំកិច្ចប្រជុំរៀបចំមាតិកាប្រវត្តិសាស្ត្រសម័យអង្គរ

វេលាម៉ោង ៨និង០០នាទីព្រឹក ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ នៅបន្ទប់ប្រជុំវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលជាការប្រជុំលើកទី១ សម្រាប់ខែកុម្ភៈ ទងនឹងការសរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យអង្គរ។ លោក **ឃិន យ៉ង់** និងលោក **សួ ប៊ុណ្ណារ៉ាត់** បានចូលរួមប្រជុំនេះ។

លោកបណ្ឌិត **វង់ សុជាវ៉ា** ប្រធានក្រុមស្រាវជ្រាវសរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យអង្គរ ដែលជាអ្នកដឹកនាំការប្រជុំបាន លើកអំពីរបៀបវារៈ ដូចខាងក្រោម៖

១. រាយការណ៍អំពីឯកសារថ្មីៗដែលសមាជិកម្នាក់ៗប្រមូលបាន

២. ការបែងចែកប្រធានបទ ដើម្បីប្រមូលឯកសារ និងសៀវភៅទាក់ទិន ដើម្បីត្រៀមសរសេរ

៣. ផ្សេងៗ



ក្រុមប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យអង្គរជួបជុំនុំនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១

# ឯកឧត្តមបណ្ឌិត ជូ ច័ន្ទដារី ប្រធានក្រុមសម័យទំនើប ដឹកនាំកិច្ចប្រជុំរៀបចំមាតិកាប្រវត្តិសាស្ត្រសម័យទំនើប

នាព្រឹកថ្ងៃចន្ទ ទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមសម័យសម័យទំនើប នៃក្រុមអ្នកសរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានប្រជុំលើកទី២ ខែកុម្ភៈ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជូ ច័ន្ទដារី** ប្រធានក្រុមសម័យកាលក្រោមរបៀបវារៈ ស្តីពី៖

- សេចក្តីព្រាងមាតិកាសម័យសង្គមរាស្ត្រនិយម
- សេចក្តីព្រាងមាតិកាសម័យសាធារណរដ្ឋខ្មែរ
- ផ្សេងៗ។

លោក **ឃិន យ៉ង់** សមាជិក លេខាធិការដ្ឋានគម្រោង បានចូលរួមប្រជុំនេះ។




ជំនុំនៃក្រុមសម័យសម័យទំនើប

# លោកបណ្ឌិត វង់ សុធារ៉ា ប្រធានក្រុមសម័យអង្គរ
# ដឹកនាំកិច្ចប្រជុំរៀបចំមាតិកាប្រវត្តិសាស្ត្រសម័យអង្គរបន្ត

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១ នៅបន្ទប់ប្រជុំវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា លោកបណ្ឌិត **វង់ សុធារ៉ា** ប្រធានក្រុមអ្នកសរសេរប្រវត្តិសាស្ត្រសម័យអង្គរ បានដឹកនាំប្រជុំក្រុមការងារអ្នកសរសេរប្រវត្តិសាស្ត្រសម័យអង្គរ លើរបៀបវារៈ ដូចខាងក្រោម៖

១. បន្តពិភាក្សាលើមាតិកា

២. ការបែងចែកប្រធានបទ ដើម្បីប្រមូលឯកសារ និងសៀវភៅទាក់ទិន ដើម្បីត្រៀមសរសេរ

៣. ពិភាក្សាលើការបញ្ចូលរាជធានីទាំងឡាយក្នុងសម័យអង្គរ។

លោក **ឃិន យ៉ង់** សមាជិក លេខាធិការដ្ឋានគម្រោង បានចូលរួមប្រជុំនេះ។




កិច្ចប្រជុំក្រុមអ្នកសរសេរប្រវត្តិសាស្ត្រសម័យអង្គរ

# ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមការអនុវត្តគម្រោងស្រាវជ្រាវ «សរសេរសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា»

ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន រួមដោយថ្នាក់ដឹកនាំ និងមន្ត្រីមួយចំនួន មានឯកទេស ប្រវត្តិវិទ្យា រដ្ឋបាលសាធារណៈ អក្សរសិល្ប៍ បានចូលរួមក្នុងគម្រោងសរសេរ «ប្រវត្តិសាស្ត្រប្រទេសកម្ពុជា» របស់ រាជបណ្ឌិត្យសភាកម្ពុជា ដែលមានឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ជាប្រធាន។ ក្នុងនោះឯកឧត្តមបណ្ឌិត **ផុន កសិកា** ជាប្រធានលេខាធិការដ្ឋាន លោក **ឃិន យ៉ង់** សមាជិកលេខាធិការដ្ឋាន លោក **សួ ប៊ុណ្ណារ៉ាត់** សមាជិកក្រុមសម័យអង្គរ លោកបណ្ឌិត **សុង ស៊ីណា** សមាជិកសម័យទំនើប។

គម្រោងនេះមានគោលបំណងចម្បង គឺបង្កើតក្រុមអ្នកសរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដែលប្រមូលផ្តុំ អ្នកប្រវត្តិសាស្ត្រខ្មែរមកពីស្ថាប័នជាតិផ្សេងៗ ដើម្បីសិក្សាស្រាវជ្រាវ និង ចងក្រងសៀវភៅ ប្រវត្តិសាស្ត្រប្រទេស កម្ពុជានៅគ្រប់សម័យកាល ដូចជា សម័យបុរេប្រវត្តិសាស្ត្រ សម័យមុនអង្គរ (សម័យហ្វូណន និង សម័យចេនឡា) សម័យអង្គរ សម័យក្រោយអង្គរ និង សម័យទំនើប។

ក្នុងនាមជាលេខាធិការដ្ឋាននៃគម្រោង យើងបានរៀបចំឱ្យសមាជិកនៃគម្រោងដែលស្ថិតនៅក្នុងសម័យ កាលទាំង៥ គឺ សម័យបុរេប្រវត្តិសាស្ត្រ, សម័យមុនអង្គរ, សម័យអង្គរ, សម័យក្រោយអង្គរ និងសម័យទំនើប រៀបចំប្រជុំក្រុមឱ្យបានទៀងទាត់ ដើម្បីពិភាក្សាគ្នាតាមក្រុមសម័យកាលឱ្យបានល្អិតល្អន់។

ជាដំណាក់កាលដំបូង ក្រុមសម័យកាលទាំងអស់នឹងសម្រេចមាតិកាតាមក្រុមនីមួយៗ រួចឆ្លងក្នុងក្រុម រួមដែលមានឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ជាប្រធានគម្រោង និងជាអង្គប្រជុំ។

# ការអនុវត្តគម្រោងស្រាវជ្រាវ «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរី កម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ច និងសង្គមកម្ពុជា»

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើគម្រោងស្រាវជ្រាវស្តីពី **«កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន ៖ សក្តានុពល បញ្ហាប្រឈម និងឱកាស សម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា»** ក្នុងគោលបំណងសិក្សានិងវិភាគអំពីសក្តានុពល តុល្យភាពនៃអត្ថប្រយោជន៍របស់កម្ពុជា បញ្ហាប្រឈម ព្រមទាំងឱកាសនានាដែលកើតមានចេញពីពាណិជ្ជកម្មសេរីកម្ពុជា-ចិន ទាំងក្នុងក្របខណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្ម និង សង្គម។ នៅក្នុងខែសីហា កញ្ញា តុលា វិច្ឆិកា ធ្នូនេះ ក្រុមការងារស្រាវជ្រាវគម្រោងនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានធ្វើការប្រជុំអនឡាញតាមប្រព័ន្ធហ្គោហ្គលមីត និងផ្ទាល់ ដើម្បីជំរុញការងារ និងបែងចែកការងារជាបន្តសម្រាប់អនុវត្តក្នុងបរិបទកូវីដ ១៩ ដើម្បីឱ្យការស្រាវជ្រាវអនុវត្តបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

នៅក្នុងខែធ្នូនេះ ក្រុមការងារស្រាវជ្រាវបានរៀបចំសរុបលទ្ធផលស្រាវជ្រាវប្រចាំឆ្នាំ ដាក់ជូនឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីពិនិត្យ និង មានអនុសាសន៍ណែនាំ។ ជាមួយគ្នានេះដែរ ក្រុមការងារស្រាវជ្រាវ បានរៀបចំឯកសារទូទាត់ថវិកាឆ្នាំ២០២១ ជូននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានគម្រោងស្រាវជ្រាវស្តីពី «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា» ដឹកនាំកិច្ចប្រជុំស្រាវជ្រាវគម្រោង ខែសីហា

នៅព្រឹកថ្ងៃសុក្រទី២០ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង៩:០០តទៅ ក្រុមស្រាវជ្រាវបានបើកកិច្ចប្រជុំ ដើម្បីតាមដានការអនុវត្តគម្រោង ក្រោមវត្តមានឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន និងជាប្រធានគម្រោង ដែលមានរបៀបវារៈដូចខាងក្រោម៖

១.ការរៀបចំជាតុចូលគម្រោង

២.ការកំណត់រៀបចំកម្មវិធីសិក្ខាសាលារកជាតុចូល ថ្ងៃទី១៧ កញ្ញា

៣. ផ្សេងៗ



# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានគម្រោងស្រាវជ្រាវស្តីពី «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា» ដឹកនាំកិច្ចប្រជុំស្រាវជ្រាវគម្រោង ខែមិថុនា

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង៩ ព្រឹក ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន និងជាប្រធានគម្រោង ព្រមទាំង លោក **លី តុង** អនុប្រធានគម្រោង លោកបណ្ឌិត **ឈឿន សារ៉េន** លោក **ឃិន យ៉ង់** លោកបណ្ឌិត **ទុយ យូឃីម** លោក **ឃិន ពោ** លោក **សាន ចេង** លោក **តូច សុធារី** សមាជិកគម្រោង «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន ៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា» ទាំងអស់ ចូលរួមប្រជុំអនឡាញ Google meet តាមរបៀបវារៈ៖

១-បច្ចុប្បន្នភាពដំណើរការស្រាវជ្រាវគម្រោង

២-ពិភាក្សាវិធីសាស្ត្រអនុវត្តគម្រោង

៣-រៀបចំកាលវិភាគចុះស្រាវជ្រាវតាមគោលដៅក្នុងខែបន្តបន្ទាប់

៤-ផ្សេងៗ



# ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានគម្រោងស្រាវជ្រាវស្តីពី «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា» ដឹកនាំកិច្ចប្រជុំស្រាវជ្រាវគម្រោង ខែឧសភា

នៅរសៀលថ្ងៃពុធ ទី២៦ ខែឧសភា ឆ្នាំ២០២១ ចាប់ពីម៉ោង១៥៖០០ ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម និងជាប្រធានគម្រោង **«កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន ៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា»** ជាគម្រោងសម្រាប់វិទ្យាស្ថានអនុវត្ត ក្នុងឆ្នាំ២០២១ បានដឹកនាំប្រជុំក្រុមការងារស្រាវជ្រាវគម្រោងតាមរយៈប្រព័ន្ធហ្សូម។ សមាសភាពអញ្ជើញចូលរួមប្រជុំ មាន លោក **លី តុង** អនុប្រធានគម្រោង លោកបណ្ឌិត **ឈឿន សាវន** លោក **យិន យ៉ង់** លោកបណ្ឌិត **ទុយ យូឃីម** លោក **យិន ពោ** លោក **សាន ចេង** លោក **តូច សុជាវី** សមាជិកគម្រោង ក្រុមការងារបានធ្វើការពិភាក្សាលើការអនុវត្ត ផែនការសកម្មភាពការងារ សេចក្តីព្រាង របាយការណ៍ ស្រាវជ្រាវ។




Zoom Meeting
You are viewing tong ly's screen
View Options
Sothiary TOCH
Navigation
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
ជំពូក ២
កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន
២.១. ទិសាលភាព និងកត្តាគតិយុត្តិ
Mute
Stop Video
Participants
Chat
Share Screen
Record
Reactions
Leave


Launch Meeting - Zoom
zoom
Zoom Meeting
You are viewing tong ly's screen
View Options
២) អំពីគម្រោង
វត្ថុបំណងទី១៖
វិស័យកសិកម្ម
វិស័យឧស្សាហកម្ម
វិស័យសិប្បកម្ម
វត្ថុបំណងទី២៖
Unmute
Stop Video
Participants
Chat
Share Screen
Record
Reactions
Leave

# ឯកឧត្តមបណ្ឌិត ផុន កសិកា និងក្រុមការងារ ចុះសិក្សាស្រាវជ្រាវ ស្វែងយល់ពីប្រវត្តិ ប្រាសាទដូនអននិងសក្តានុពលទេសចរណ៍

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា អមដំណើរដោយលោក **សួ ប៊ុណ្ណារ៉ាត់** ប្រធាននាយកដ្ឋានប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រនយោបាយ និងលោក **ឃិន ពោ** អនុប្រធាននាយកដ្ឋាននីតិសាស្ត្រ បានចុះសិក្សាស្រាវជ្រាវ ស្វែងយល់ពីប្រវត្តិ ប្រាសាទដូនអននិងសក្តានុពលទេសចរណ៍ ដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅភូមិប្រាសាទ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ក្នុងគោលបំណងដើម្បី៖

•សិក្សាប្រវត្តិប្រាសាទដូនអនដែលពាក់ព័ន្ធនិងសម័យកាលសាងសង់ប្រាសាទ និងការរុះរើបំផ្លាញប្រាសាទ

•សិក្សាស្រាវជ្រាវបែបបុរាណវត្ថុវិទ្យា ប្រវត្តិសិល្បៈ ធ្វើផែនទីស្ថានីយ៍ និងសក្តានុពលទេសចរណ៍នៅតំបន់នោះ

ជាមួយគ្នានេះដែរ ក្រុមការងារបានចុះសម្ភាសន៍ផ្ទាល់ ជាមួយអាជ្ញាធរដែនដី ព្រះចៅអធិការវត្តដូនអន លោកតាអាចារ្យវត្ត តាជី យាយជី និងប្រជាពលរដ្ឋរស់នៅទីនោះ ដើម្បីចងក្រងទុកជាឯកសារនូវសម្បត្តិវប្បធម៌ដ៏មានតម្លៃនេះ ក្នុងការជួយជំរុញ ព្រមទាំងបណ្តុះស្មារតីកូនខ្មែរជំនាន់ក្រោយឱ្យពួកគេចេះស្រឡាញ់ ចេះថែរក្សា ចេះការពារ និងសិក្សាស្រាវជ្រាវបន្តទៀត ។




# លោកបណ្ឌិត ឈឿន សាវន ចុះសិក្សា
# ស្រាវជ្រាវនៅសហគមន៍អេកូទេសចរណ៍ធម្មជាតិកោះទ្រុង

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ លោកបណ្ឌិត **ឈឿន សាវ៉ន** ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ច និងទេសចរណ៍ បានចុះសិក្សាស្រាវ ជ្រាវនៅសហគមន៍អេកូទេសចរណ៍ធម្មជាតិកោះទ្រុង ខេត្តក្រចេះ។






# ឯកឧត្តមបណ្ឌិត ផុន កសិកា ដឹកនាំកិច្ចប្រជុំរៀបចំ កលិកប័ត្រមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

នៅព្រឹកថ្ងៃអង្គារ ទី២៥ ខែឧសភា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩ តទៅ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានដឹកនាំកិច្ចប្រជុំរៀបចំកលិកប័ត្រមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម សម្រាប់លេខទី១ ឆ្នាំ២០២១ តាមរយៈ ប្រព័ន្ធហ្សូម។ សមាសភាពចូលរួមប្រជុំ មានលោក **ឃិន យ៉ង់** ទទួលបន្ទុកនាយកដ្ឋានកិច្ចការទូទៅ លោក **លី តុង** នាយកដ្ឋានវិទ្យាសាស្ត្រអប់រំ និងជាអ្នកទទួលបន្ទុកការងារកលិកប័ត្រ លោកបណ្ឌិត **ឈឿន សាវន** នាយកដ្ឋានសេដ្ឋកិច្ចនិងទេសចរណ៍ ជាជ័យលាភីស្រាវជ្រាវ លោក **សួ ប៉ុណ្ណារ៉ាត់** នាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ ជាជ័យលាភីស្រាវជ្រាវ លោក **ហៃ សុគន្ធា** នាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម ជាជ័យលាភីស្រាវជ្រាវ លោក **តូច សុធារី** នាយកដ្ឋានវិទ្យាសាស្ត្រអប់រំ ជាជ័យលាភីស្រាវជ្រាវ លោក **ឆោម ជុំរ៉ុង** ជាជ័យលាភីស្រាវជ្រាវ លោក **មឿង ចំរើន** ជាជ័យលាភីស្រាវជ្រាវ។

ឯកឧត្តមបណ្ឌិត **ផុន កសិកា** បានប្រកាសអំពីជ័យលាភីដែលត្រូវធ្វើកិច្ចការស្រាវជ្រាវ ការឧបត្ថម្ភកិច្ចការស្រាវជ្រាវ និងជំរុញលើកទឹកចិត្តជ័យលាភីទាំងអស់ឱ្យខិតខំធ្វើការស្រាវជ្រាវ ដើម្បីសរសេរអត្ថបទចុះផ្សាយក្នុងកលិកប័ត្រ។




Zoom Meeting
Home Tools Document
Sign In
បញ្ជាក់៖
tong ly
Sothiary TOCH
Kaseka Phon
Apsara Khmer
10:23 AM
5/25/2021


Zoom Meeting
tong ly
Kaseka Phon
Apsara Khmer
Home Tools Document
Sign In
(Journal of Humanities and Social Sciences)
Website: https://ihssacademy.com/
Students' Engagement and Academic Writing Performance: A Case of English Major Junior Undergraduates in Cambodia
Chumrong CHHOM[1] and Tong LY[2]
1 Secretariate of Academicians, Royal Academy of Cambodia
Email: abcsded@gmail.com
2 Institute of Humanities and Social Science, Royal Academy of Cambodia
Email: lytongcambodia2013@gmail.com
Received: October 12, 2021; Accepted: December 10, 2021; Published: December 20, 2021
To cite this article: Chhom, C. & Ly, T. (2021). Students' Engagement and Academic Writing Performance: A Case of English Major Junior Undergraduates in Cambodia. Journal of Humanities and Social Sciences, 1(1), p. 1-18.
ABSTRACT
opinion.
KEYWORDS: Students' engagement, academic writing, learning performance, Cambodia, relationship
Search Tools...
Create PDF
Edit PDF
Export PDF
Comment
Organize Pages
Enhance Scans
Protect
Fill & Sign
Prepare Form
Send for Signature
Send & Track
ENG
9:35 AM
5/25/2021

# ឯកឧត្តមបណ្ឌិត ផុន កសិកា និងក្រុមការងារ ចុះសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមអំពី «ប្រព័ន្ធធារាសាស្ត្រនៅភាគខាងជើងបន្ទាយលង្វែក»

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន និងក្រុមការងារស្រាវជ្រាវនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម អមដំណើរដោយលោក **សួ ប៉ុណ្ណារ៉ាត់** ប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ និងលោក **ឃិន ពោ** អនុប្រធាននាយកដ្ឋាននីតិសាស្ត្រ បានចុះសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមអំពី **«ប្រព័ន្ធធារាសាស្ត្រនៅភាគខាងជើងបន្ទាយលង្វែក»** ដែលតំបន់នេះស្ថិតក្នុងឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

ការសិក្សានេះធ្វើឡើងតាមរយៈរូបភាពពីលើអាកាស (ប្រភព៖ Google Earth) និងការចុះផ្ទាល់ដល់ទីតាំងស្ថានីយ៍ដែលបានកំណត់តាមរូប Google Earth។

ក្រុមស្រាវជ្រាវបានរកឃើញស្ថានីយ៍បុរាណចំនួនពីរ (២) ទីតាំងដែលស្ថិតក្នុងភូមិកំពង់ត្រឡាចលើ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលមិនមែនជាសំណង់ធារាសាស្ត្រទេ ប៉ុន្តែជាសំណង់ទាក់ទងនឹងប្រាសាទបុរាណ។

ស្ថានីយ៍បុរាណទី១មានឈ្មោះថា «ទួលជំនីក» គឺជាស្ថានីយ៍មានកំពែងដីលើករាងចតុកោណកែង ស្ថិតលើអក្សកើតលិច ដែលអក្សកើតលិចនេះប្រវែង ៤១០ម៉ែត្រ និងអក្សជើងត្បូងប្រវែង ២៥០ម៉ែត្រ និងទទឹងកំពែងប្រវែង ៣០ម៉ែត្រ។ នៅក្នុងបរិវេណកំពែងនេះ មានទួលមួយស្ថិតងាកមកភាគខាងលិចបន្តិចនៃជ្រុងកំពែងខាងលិច។ ទួលនេះមានប្រវែងពីកើតទៅលិច ប្រហាក់ប្រហែល ១០០ម៉ែត្រ និង ពីជើងទៅត្បូង ប្រវែងប្រហែល ៧០ម៉ែត្រ។ លក្ខណៈនេះមានសណ្ឋានដូចកំពែងព័ទ្ធជុំវិញប្រាសាទ ចំណែកទួលនៅខាងក្នុងក៏ជាលក្ខណៈនៃទួលប្រាសាទ។

តាមការអង្កេតផ្ទៃដីខាងលើ មិនមានដុំថ្មភក់ ឬ ថ្មបាយក្រៀម ដែលជាធាតុនៃសំណង់ប្រាសាទខ្មែរបុរាណ។ តាមសណ្ឋានរូបរាងបែបនេះ សំណង់កំពែង និង ទួលក្នុងបរិវេណកំពែងជាធាតុនៃប្រាសាទបុរាណដែលប្រហាក់ប្រហែលគ្នានឹងសំណង់ប្រាសាទក្នុងសម័យអង្គរ។

ចំណែកស្ថានីយ៍ទី២ ស្ថិតនៅខាងត្បូងទួលជំនីក ចម្ងាយប្រមាណតែ៦០ម៉ែត្រប៉ុណ្ណោះ។ ទួលនេះត្រូវបានអ្នកភូមិនៅទីនោះហៅឈ្មោះថា «ទួលវិហារខុស»។ ទួលនេះមានទំហំស្មើរស្មើគ្នា កម្ពស់ខ្ពស់ និងមានគូទឹកព័ទ្ធជុំវិញគួរឱ្យកត់សម្គាល់។ សណ្ឋានសំណង់ដីបែបនេះក៏ជាលក្ខណៈនៃសំណង់ប្រាសាទខ្មែរ ក្នុងសម័យមុនអង្គរ។

ទោះយ៉ាងណាការសន្និដ្ឋានខាងលើពិតជាមិនទាន់មានអំណះអំណាងមាំទាំនៅឡើយទេ ដោយសារមិនមានសំណល់បុរាណវត្ថុសម្រាប់ផ្តល់ជាភ័ស្តុតាងក្នុងការកំណត់អាយុកាលស្ថានីយ៍។

ដោយហេតុ ទីតាំងស្ថានីយ៍កំពុងមានសកម្មភាពឈូសឆាយដីដោយគ្រឿងយន្តនៅក្នុងកំពែង ទួលជំនីក ហើយស្ថានីយ៍ទាំងពីរមិនមានក្នុងបញ្ជីប្រាសាទរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ក្រុមស្រាវជ្រាវមានការព្រួយបារម្ភចំពោះការបំផ្លាញស្ថានីយ៍នេះ ដោយមិនមានការយកចិត្តទុកដាក់ពីអាជ្ញាធរជំនាញនៅមូលដ្ឋាន។





សកម្មភាពចុះសិក្សាអង្កេតដល់ទីតាំងស្ថានីយ៍ និងការធ្វើសម្ភាសជាមួយប្រជាពលរដ្ឋរស់នៅក្បែរស្ថានីយ៍

# ឯកឧត្តមបណ្ឌិត ផុន កសិកា
# ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
# សហការជាមួយអ្នកស្រាវជ្រាវអន្តរជាតិមកពីសាលាបារាំងចុងបូព៌ា
# ធ្វើការសិក្សាស្រាវជ្រាវនៅតំបន់ស្រុកឆែប ខេត្តព្រះវិហារ

ចាប់ពីថ្ងៃទី២២ ដល់ ២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត ផុន កសិកា និង លោក សួ ប៉ុណ្ណារ៉ាត់ បានចុះសិក្សាស្រាវជ្រាវ ដោយរួមសហការជាមួយអ្នកស្រាវជ្រាវអន្តរជាតិមកពីសាលាបារាំងចុងបូព៌ា ដែលដឹកនាំដោយលោកបណ្ឌិត Brice Vincent (នាយកសាលាបារាំងចុងបូព៌ា) នៅតំបន់ស្រុកឆែប ខេត្តព្រះវិហារ។

គោលបំណងនៃការសិក្សានេះ ដើម្បីស្វែងរកនិងស្វែងយល់បន្ថែមអំពី ឡស្លលោហៈ ដូចជា លោហៈដែក និងលោហស្ពាន់។

ការសិក្សាស្រាវជ្រាវបានផ្តោតនៅលើទីតាំង ១-ឡស្លែដកនៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប និង ២/ឡស្លដែកនៅត្រពាំងជាន់សន្លុង ភ្នំកូនធ្លៃ និង ត្រពាំងទោល ស្ថិតក្នុងឃុំឆែប១ ស្រុកឆែប ខេត្តព្រះវិហារ។




ទីតាំងស្រាវជ្រាវនៅខែវិច្ឆិកា ឆ្នាំ២០២២



ទិដ្ឋភាពកត់ត្រាចំណុចទួលឡស្លស្តាន់



កិច្ចស្វាគមន៍របស់ឯកឧត្តម សូត្រ សំណាង



ថ្នាក់ដឹកនាំឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប និង ក្រុមស្រាវជ្រាវ

# ឯកឧត្តមបណ្ឌិត ផុន កសិកា
# ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
# ប្រជុំពិភាក្សាជាមួយ
# លោកបណ្ឌិត Brice Vincent ប្រធានសាលាបារាំងចុងបូព៌ា

នារសៀលថ្ងៃពុធ ទី១៦ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមប្រជុំពិភាក្សា តាមប្រព័ន្ធអនឡាញ Zoom meeting ជាមួយលោកបណ្ឌិត **Brice Vincent** ប្រធានសាលាបារាំងចុងបូព៌ា (EFEO) នៃខេត្តសៀមរាប និងសហការី លោក **Sebastien Clouet** ស្តីពីកិច្ចសហការណ៍គម្រោងស្រាវជ្រាវនាពេលអនាគត រវាងវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រើប នៃរាជបណ្ឌិត្យសភាកម្ពុជា និងសាលាបារាំងចុងបូព៌ា EFEO។



# ឯកឧត្តមបណ្ឌិត ផុន កសិកា
# ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
# ទទួលជួបពិភាក្សាការងារជាមួយលោក ហង្ស និស្ស័យ
# ប្រធានសារមន្ទីរទួលស្លែង

នៅថ្ងៃសៅរ៍ ១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា បានទទួលជួបលោក **ហង្ស និស្ស័យ** ប្រធានសារមន្ទីរទួលស្លែង និងសហការី ដើម្បីពិភាក្សាស្វែងរកលទ្ធភាពក្នុងការសហការណ៍ធ្វើការងារស្រាវជ្រាវប្រវត្តិសាស្ត្រ និងការផលិតឯកសារសោទស្សន៍ (វីដេអូឯកសារ)។



ជំនួបរវាងឯកឧត្តមប្រធានវ.ម.វ.ស និងក្រុមការងារសារមន្ទីរទួលស្លែង

# ការងារយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថាន

វិទ្យាស្ថាន បានរៀបចំក្រុមរៀបចំផែនការនិងយុទ្ធសាស្ត្រ សម្រាប់អនុវត្តក្នុងវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមក្នុងឆ្នាំ២០២១នេះ។ សមាសភាពក្រុមរៀបចំមានដូចជា៖

១-ឯកឧត្តមបណ្ឌិត ផុន កសិកា

២-លោក លី តុង

៣-លោក ឃិន យ៉ង់

៤-លោក ឈឿន សាវ៉ន

៥-លោក ឃិន ពោ

៦-លោក សាន ចេង

៧-លោក នេត ចំរើន

៨-លោក គួច សុធារី

គោលបំណងគឺដើម្បីផ្តល់ជាគំនិតខ្លះៗ ដើម្បីជំរុញការងារទូទៅរបស់វិទ្យាស្ថាន កិច្ចការងារស្រាវជ្រាវ ព្រមទាំងពង្រឹងការងារបោះពុម្ពអត្ថបទនានាទាំងក្នុង "**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**" ដែលមានស្រាប់ និងការបង្កើតនូវ ប្រភេទនៃការបោះពុម្ពថ្មីដែលមានឈ្មោះថា "**កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**" នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។

ក្រុមសមាជិករៀបចំយុទ្ធសាស្ត្របានប្រជុំចំនួន ២លើក ដោយបានលើកយកចំណុចសំខាន់មួយ គឺការជំរុញការស្រាវជ្រាវក្នុងរង្វង់នាយកដ្ឋាន និងមន្ត្រីម្នាក់ៗ នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។ លទ្ធផលនៃការស្រាវជ្រាវនឹងផ្សព្វផ្សាយតាមរយៈ ព្រឹត្តិប័ត្រ, ទស្សនាវដ្តី កលិកប័ត្រស្រាវជ្រាវ វីដេអូឯកសារ, គេហទំព័រ និង ផេកហ្វេសប៊ុក។

ផែនការយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថាន បង្កើតឡើងស្របទៅតាមដំណើរប្រព្រឹត្តិទៅនៃរាជបណ្ឌិត្យសភាកម្ពុជា គឺពាក់ព័ន្ធនឹងការជំរុញការស្រាវជ្រាវតាមនាយកដ្ឋានជំនាញទាំងអស់ដែលស្ថិតនៅក្រោមវិទ្យាស្ថាននិងមន្ត្រីជំនាញឱ្យបង្កើនការស្រាវជ្រាវសម្រាប់ផលិតជាស្នាដៃបោះពុម្ពផ្សាយ និង ផ្សព្វផ្សាយតាមប្រព័ន្ធសង្គម (គេហទំព័រ និង ហ្វេសប៊ុក)។

គោលបំណងគឺដើម្បីផ្តល់ជាគំនិតខ្លះៗ ដើម្បីជំរុញការងារទូទៅរបស់វិទ្យាស្ថាន កិច្ចការងារស្រាវជ្រាវ ព្រមទាំងពង្រឹងការងារបោះពុម្ពអត្ថបទនានាទាំងក្នុង "**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**" ដែលមានស្រាប់ និងការបង្កើតនូវ ប្រភេទនៃការបោះពុម្ពថ្មីដែលមានឈ្មោះថា "**កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**" នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។

ក្រុមសមាជិករៀបចំយុទ្ធសាស្ត្របានប្រជុំចំនួន ២លើក ដោយបានលើកយកចំណុចសំខាន់មួយ គឺការជំរុញការស្រាវជ្រាវក្នុងរង្វង់នាយកដ្ឋាន និងមន្ត្រីម្នាក់ៗ នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។ លទ្ធផល

នៃការស្រាវជ្រាវនឹងផ្សព្វផ្សាយតាមរយៈ ព្រឹត្តិប័ត្រ, ទស្សនាវដ្តី កលិកប័ត្រស្រាវជ្រាវ វីដេអូឯកសារ, គេហទំព័រ និង ផេកហ្វេសប៊ុក។



កិច្ចប្រជុំក្រុមរៀបចំយុទ្ធសាស្ត្រសម្រាប់ វ.ម.វ.ស

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានរៀបចំសំណើគម្រោងស្រាវជ្រាវស្តីពី «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន ៖ សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា» ក្នុងគោលបំណងសិក្សានិងវិភាគអំពីសក្តានុពល តុល្យភាពនៃអត្ថប្រយោជន៍របស់កម្ពុជា បញ្ហាប្រឈមព្រមទាំងឱកាសនានាដែលកើតមានចេញពីពាណិជ្ជកម្មសេរីកម្ពុជា-ចិន ទាំងក្នុងក្របខណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្មនិងសង្គម។ តាមរយៈលទ្ធផលនៃការស្រាវជ្រាវនេះ យើងនឹងរៀបចំជាគំនិតគោលនយោបាយជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីទាញយកផលប្រយោជន៍ឱ្យបានជាអតិបរមាសម្រាប់វឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គមកម្ពុជា លើគ្រប់វិស័យ។ ការសិក្សាស្រាវជ្រាវគម្រោងនេះប្រើរយៈពេល១០ (ដប់)ខែ គ្រោងនឹងត្រូវចំណាយអស់ថវិកាសរុបចំនួន ១៥០ ០០០ ០០០៛ (មួយរយហាសិបលានរៀលគត់) ដោយមានសមាជិក ៧រូប មានឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន ជាប្រធានគម្រោង។ ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានរាជបណ្ឌិតសភាកម្ពុជា បានអនុម័តគម្រោងខាងលើដល់វិទ្យាស្ថានមនុស្សសាស្ត្រសម្រាប់អនុវត្តក្នុងឆ្នាំ២០២១។ លោក **លី តុង** បានរៀបចំសរសេរគម្រោង និងបានដាក់បញ្ជូនទៅនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រួចរាល់ហើយដែរ។

ក្នុងខែកុម្ភៈ វិទ្យាស្ថាន បានកែលិខិត និងទម្រង់គម្រោងឡើងវិញ ហើយបានដាក់ទៅរដ្ឋបាលរាជបណ្ឌិត្យសភាកម្ពុជា។

# ការងារថតវីដេអូឯកសាររបស់វិទ្យាស្ថាន

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ក៏បានបង្កើតក្រុមក្នុងវិទ្យាស្ថានសម្រាប់ថតវីដេអូ បង្កើតជាបទយកការណ៍វីដេអូ វីដេអូខ្លី។

ក្រុមការងារគម្រោង «កំណត់អត្តសញ្ញាណបដិមា ព្រះបាទជ័យវរ្ម័នទី៧» បានចុះមកថត ដើម្បីផលិតវីដេអូឯកសារ ស្តីពីលទ្ធផលស្រាវជ្រាវ ដោយមានការចូលរួមធ្វើអត្ថាធិប្បាយ ដោយឯកឧត្តមបណ្ឌិត យង់ ពៅ អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា, ឯកឧត្តមបណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម និងលោក ឡេង សិត្យា មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា។

ផលិតកម្មវីដេអូឯកសារនេះនិងកាត់តដោយក្រុមផលិតវីដេអូ នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។



ដំណើរការផលិតវីដេអូខ្លី ស្តីពី «អត្តសញ្ញាណព្រះបាទជ័យវរ្ម័នទី៧» នៅប្រាសាទបាយ័ន

វិទ្យាស្ថានមនុស្សសាស្ត្រក៏បានបង្កើតក្រុមក្នុងវិទ្យាស្ថានសម្រាប់ថតវីដេអូ បង្កើតជាបទយកការណ៍វីដេអូ វីដេអូខ្លី។ កន្លងមកក្រុមការងារក៏បានថតវីដេអូអំពី «ដំណើរការសរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជា» ដែលមានលោក ឃិន យ៉ង់, លោក នេត ចំរើន និង កញ្ញា តាកេត ស័កដា ជាអ្នកថត និង ធ្វើសម្ភាសន៍។



ការថតវីដេអូអំពីសកម្មភាពប្រជុំ និងកិច្ចសម្ភាសន៍ក្រុមសម័យក្រោយអង្គរ

# ការពារសង្គម

# ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមរំលែកមរណទុក្ខក្រុមគ្រួសារថ្នាក់ដឹកនាំនិងមន្ត្រី នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលមានសមាជិកគ្រួសារទទួលមរណភាព

ក.នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម រួមដំណើរដោយលោក **សួ ប៉ុណ្ណាវ៉ាត់** ប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ លោក **ឃិន ពោ** អនុប្រធាននាយកដ្ឋានបានអញ្ជើញចូលរួមក្នុងពិធីបុណ្យមរណទុក្ខ ឧបាសក **សូរ សុផល** ត្រូវជាឪពុកបង្កើតរបស់លោក **ប្រែង ពិសិដ្ឋ** ប្រធាននាយកដ្ឋានកិច្ចការទូទៅ វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៅគេហដ្ឋាននៃសព នាស្រុកបាកាន ខេត្តពោធិ៍សាត់។



ខ.វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលរួមរំលែកមរណទុក្ខឧបាសក **ឃ្លាំង គីមលាង** ត្រូវជាឪពុកក្មេករបស់លោក វ៉ាត សុផាន មន្ត្រីវិទ្យាស្ថានភាសាជាតិ។

គ.វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលបុណ្យរំលែកមរណទុក្ខឧបាសក **ស្វាយ ផល** ត្រូវជាឪពុកបង្កើតរបស់លោក ស្វាយ ចាន់មុនី មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានរាជបណ្ឌិត្យសភាកម្ពុជា។

ឃ.វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលបុណ្យរំលែកមរណទុក្ខឯកឧត្តម **ម៉ន សម្បត្តិ**
បច្ច័យ ៤០ម៉ឺនរៀល

| | | |
|---|---|---|
| ឯកឧត្តមបណ្ឌិត ផុន កសិកា និងលោកជំទាវ | ចូលបុណ្យ | ២០ម៉ឺនរៀល |
| លោក ឃិន យ៉ង់ | ចូលបុណ្យ | ១០ម៉ឺនរៀល |

| | | |
|---|---|---|
| លោកបណ្ឌិត ហែម ឡាច | ចូលបុណ្យ | ១០ម៉ឺនរៀល |
| លោកបណ្ឌិត ប៉ាន់ វុត្ថា | ចូលបុណ្យ | ១០ម៉ឺនរៀល |
| លោក សួ ប៊ុណ្ណារ៉ាត់ | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក សាន ចេង | ចូលបុណ្យ | ៥ម៉ឺនរៀល |
| | សរុបបច្ច័យ | ១ ០០០ ០០០រៀល។ |

ឯកឧត្តមបណ្ឌិត ផុន កសិកា លោក សួ ប៊ុណ្ណារ៉ាត់ លោក ឃិន ពោ លោកបណ្ឌិត ហែម ឡាច លោកបណ្ឌិត ប៉ាន់ វុត្ថា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យសព និងពិធីបូជាសព ឯកឧត្តម ម៉ន សម្បត្តិ ។

ង.វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលបុណ្យរំលែកមរណទុក្ខមាតាក្មេក លោក ជា សម្បត្តិ

| | | |
|---|---|---|
| | បច្ច័យ | ២០ម៉ឺនរៀល |
| ឯកឧត្តមបណ្ឌិត ផុន កសិកា និងលោកជំទាវ | ចូលបុណ្យ | ១០ម៉ឺនរៀល |
| លោក ឃិន យ៉ង់ | ចូលបុណ្យ | ១០ម៉ឺនរៀល |
| លោកបណ្ឌិត ហែម ឡាច | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក សួ ប៊ុណ្ណារ៉ាត់ | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក ហៃ សុគន្ធា | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក សាន ចេង | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោកបណ្ឌិត សូ សុធីរ | ចូលបុណ្យ | ៥ម៉ឺនរៀល |
| | សរុបបច្ច័យ | ៦៥០ ០០០រៀល។ |

ច.វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ចូលបុណ្យរំលែកមរណទុក្ខលោកគ្រូ អៀម សំរិទ្ធ (បិតា លោកស្រី សំរិទ្ធ ចរិយា លោកស្រី សំរិទ្ធ ទេពី) បច្ច័យ ២០ម៉ឺនរៀល

ឯកឧត្តមបណ្ឌិត ផុន កសិកា និងលោកជំទាវ ចូលបុណ្យ ២០ម៉ឺនរៀល (វេរទៅលោកស្រីទេពី)

| | | |
|---|---|---|
| លោកស្រីបណ្ឌិត ព្រុំ ទេវី | ចូលបុណ្យ | ៣០$ (តាមរយៈក្រុមនារី របសក) |
| ឯកឧត្តមបណ្ឌិត កង ឱម | ចូលបុណ្យ | ១០ម៉ឺនរៀល |
| លោក ឃិន យ៉ង់ | ចូលបុណ្យ | ១០ម៉ឺនរៀល |
| លោក សួ ប៊ុណ្ណារ៉ាត់ | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោកបណ្ឌិត ហែម ឡាច | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក ប៉ាន់ សំណាង | ចូលបុណ្យ | ៤ម៉ឺនរៀល |
| លោកបណ្ឌិត សុង ស៊ីណា | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក ហៃ សុគន្ធា | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោកបណ្ឌិត ប៉ាន់ វុត្ថា | ចូលបុណ្យ | ៥ម៉ឺនរៀល |

| | | |
|---|---|---|
| លោក សាន ចេង | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក មាឃ សារី | ចូលបុណ្យ | ៥ម៉ឺនរៀល |
| លោក ឃិន ពោ | ចូលបុណ្យ | ៤ម៉ឺនរៀល |
| លោកបណ្ឌិត សូ សុធីរ | ចូលបុណ្យ ១០ម៉ឺនរៀល (វេរទៅលោកស្រី ចរិយា) | |
| លោកបណ្ឌិត ហ៊ឹម ញាណារិទ្ធ | ចូលបុណ្យ | ៥ម៉ឺនរៀល |
| កញ្ញា តាកេត ស័កដា | ចូលបុណ្យ | ៦ម៉ឺនរៀល |

# ឯកឧត្តមបណ្ឌិត ផុន កសិកា អញ្ជើញចុះស្វែងយល់ពី ស្ថានភាពទូទៅរបស់ប្រជាពលរដ្ឋ នៅភូមិព្រៃដក់ពរ

នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា រួមដំណើរដោយលោកបណ្ឌិត **ឈឿន សាវន** ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងទេសចរណ៍ លោក **យិន ពោ** អនុប្រធាននាយកដ្ឋាននីតិសាស្ត្រ និងលោក **សាន ចេង** មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងទេសចរណ៍ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខជាមួយមេភូមិព្រៃដក់ពរ ដើម្បីស្វែងយល់ពីស្ថានភាពទូទៅរបស់ប្រជាពលរដ្ឋនៅភូមិព្រៃដក់ពរ។ ភូមិព្រៃដក់ពរ ជាភូមិមួយក្នុងចំណោមភូមិទាំង១១ របស់ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ខេត្តតាកែវ។ ភូមិនេះមានប្រជាជនចំនួន ៩៣គ្រួសារ សរុប ៤៦៧នាក់ ស្រីចំនួន ២៦៣នាក់។ ក្នុងភូមិមានទីតាំងអនុវិទ្យាល័យមួយកន្លែង ឈ្មោះអនុវិទ្យាល័យព្រៃដក់ពរ។ ក្នុងភូមិមានស្រះសហគមន៍មួយកន្លែងជាកន្លែងអភិរក្សពូជត្រី និងជាប្រភពផ្ដល់ទឹកសម្រាប់ប្រើប្រាស់ក្នុងរដូវប្រាំងដល់ប្រជាជននៅជុំវិញនោះ។ ក្រៅពីនេះ នៅតាមដីភូមិនដ្ឋានរបស់ប្រជាជន មានដីកស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ដាំដំណាំ រុក្ខជាតិនានា បន្ថែមពីលើការធ្វើស្រែវស្សាផងដែរ។ ប្រជាជនភាគច្រើនគោរពព្រះពុទ្ធសាសនា នៅក្នុងឃុំត្រពាំងធំខាងជើងមានវត្តចំនួនបី គឺវត្តមង្គលមានលក្ខណ៍ វត្តពោធិ៍រុន និងវត្តសិរីដំណាក់ ដែលផ្ដល់ភាពងាយស្រួលដល់ប្រជាជនក្នុងការធ្វើពិធីបុណ្យទាននានាតាមប្រពៃណីព្រះពុទ្ធសាសនា។





ទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត ចងភ្ជាប់ដោយលទ្ធផល
ហើយត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ